Free

សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us

Advertising: 978-656-8141/ Hotline news: 978-942-1641

7 Video

ទទួលផ្ញើអីវ៉ាន់ ទៅវិញទៅមកស្រុកខ្មែរ

- ផ្ញើ១ផោន តម្លៃ ១០ដុល្លារ
- ធានា បើសិន បាត់ ឬបាក់បែក
- ដឹកជញ្ជូនដល់ផ្ទះ

ទំនាក់ទំនង ៖ Mr. យុទ្ធ (978) 876-1985

660 Middlesex St., Lowell, MA 01851

(978)710-6356

# MINISTRY WORKING ON REVISION OF US REPATRIATION AGREEMENT

by KhySovuthy | March 1, 2017

In an effort to keep Cambodians threatened with deportation in the U.S. with their families, the Foreign Affairs Ministry plans to offer the U.S. a revised version of the countries' repatriation



Foreign Minister PrakSokhonn speaks during an annual meeting at the ministry's headquarters in Phnom Penh on Tuesday. (Emil Kastrup/The Cambodia Daily)

agreement, an official said on Tuesday.

The ministry has been reviewing the 2002 memorandum of understanding (MoU), which allows for the deportation of Cambodians convicted of felonies in the U.S., **Continued to Page 14**

# បុណ្យចូលឆ្នាំថ្មីឆ្នាំរកានៅសហរដ្ឋអាមេរិក

**ដោយ សុខាវ័ត្ន កូយ**

ឡូវែល- ឆ្នាំនេះ ប្រជាពលរដ្ឋនៅឡូវែល នឹងនៅតំបន់ឯទៀត ប្រារព្ធពិធីបុណ្យចូលឆ្នាំរបស់ខ្លួន នៅវត្តចាប់ពីថ្ងៃសុក្ររហូតដល់ថ្ងៃអាទិត្យដូចៗគ្នាគាប់ជួនជាពេលមានថ្ងៃល្អថែមទៀតនោះ ប្រជាពលរដ្ឋក៏ចូលរួមបានច្រើន រីឯគណកម្មការវត្ត ក៏រៀបចំវត្តបានល្អស្អាតសម្រាប់ប្រារព្ធពិធីផងដែរ។ សាលាក្រុងនៃតំបន់ដែលមានសហគមន៍ខ្មែរច្រើនរស់នៅបានលើកទង់ជ័យខ្មែរឡើង សម្រាប់ជូនជាកិត្តិយសដល់ពិធីជាប្រពៃណីខ្មែរផងដែរ។

ជារៀងរាល់ឆ្នាំនៅពាក់កណ្តាលខែមេសា ប្រជាពលរដ្ឋខ្មែរតែងតែប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីដែល **តទៅទំព័រទី ១៥**



ពិធីរាប់បាតនៅវត្តខ្មែររ៉ូដអាយឡិននាឱកាសចូលឆ្នាំរកា

# ចរន្ត២នៃអនាគតវិទ្យាល័យឡូវែលនៅ“ក្នុងក្រុង”ឬ“ក្រៅក្រុង”?

## New LHS: Pro "Downtown" or Pro "Cawley"why?

**ដោយ ពិន សំខុន**

ឱកាសដ៏កំររបំផុតមួយបានកើតឡើងស្ទើរតែ១០០ឆ្នាំទើបកើតមានម្តងសម្រាប់អនាគតសិក្សាយុវជននៅឡូវែល នៅពេលដែលរដ្ឋាភិបាល បច្ចុប្បន្នមានថវិការថ្មី ហើយសួរយោបល់ពលរដ្ឋថា "តើគួរសង់កែរលំអវិទ្យាល័យឡូវែលនៅក្នុងក្រុងលើកន្លែងដដែល?" ឬក៏"ទៅសង់វិទ្យាល័យថ្មីស្រឡាងមួយនៅតំបន់ខលីខាងក្រៅក្រុងឡូវែល?"។ ពលរដ្ឋឡូវែលបានផ្តើមពិគ្រោះគ្នាលើដំណឹងដែលគ្រប់មាតាបិតាតែងប្រាថ្នានូវអ្វីដែលប្រសើរបំផុតសម្រាប់ការសិក្សាកូនរបស់ខ្លួន។ **តទៅទំព័រទី 0៤**




ចរន្តអ្នកចង់ឱ្យវិទ្យាល័យឡូវែលនៅកណ្តាលក្រុង

មេធាវី លុយហាស្កែល

Law Office of Louis S. Haskell

Serving the Cambodian Community since 1987

PERSONAL INJURY រងរបួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359

16 Pine Street - Lowell, MA | www.attorneyhaskell.com

សារព័ត៌មាន ខ្មែរប៉ុស្ត៍ ស.រ.អា

KhmerPost USA

Cambodian American Biweekly Newspaper

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:
- Lowell
- Lynn/Revere

Rhode Island:
- Providence
- Cranston

CELEBRATING 10 YEARS

Contact us for the Advertising Opportunity!

978-677-7163 | http:/khmerpost.us

ខ្មែរប៉ុស្តិ៍
KhmerPost USA

We Cordially Invites You To Our

# 10th Anniversary Gala

**Friday, May 19, 2017**
**6:00PM – Midnight**

**UMASS Lowell Inn & Conference Center**
50 Warren Street, Lowell, Massachusetts



**Soben Pin**
*Co-founder & Managing Partner*



**Roger Samkhon Pin**
*Editor & Publisher*

COCKTAIL HOUR 5:30 - 6:30 PM
SERVING HORS D'OEUVRES

CULTURAL PERFORMANCES

DINNER • LIVE BAND & DANCING

CASH BAR • SILENT AUCTIONS

**$75 per ticket**
**$700 per table of 10**
*No Tickets Sold at the Door*
*Black Tie Optinal*

**Please RSVP by Wednesday May 10th**
Contact: 978-677-7163 or
sobenpin@khmerpost.us



## FEATURED SPEAKERS



**Andy Pendelton**
*Former United Nations Field Coordinator Thai Refugee Camps (1980-1990s)*



**Hong Net**
*City of Lynn Councilor-at-Large*



**Cheryl A. Burrell**
*Associate Director Rhode Island Dept. of Administration Office of Diversity, Equity and Opportunity (ODEO)*

# Thank You to Our Sponsors

*Silver Sponsor*
**Senior Whole Health**

*Bronze Sponsors*
**Dolan Funeral Home • Fallon Health • Lowell Spinners**
**Lynn Primary Care Center**

# ប្រធានាធិបតី“ឌណាល ត្រម”កាន់កាប់សេដ្ឋវិមានបាន១០០ថ្ងៃហើយ

**ខ្មែរផុសស.រ.អា.**

គ្មានសកម្មភាពអ្វីដែលគួរឱ្យភ្ញាក់ផ្អើលទេ មានតែព្រឹត្តិការណ៍ផ្លែកៗ នៅរយពេល១០០ថ្ងៃនៃអំណាចថ្មីរបស់ប្រធានាធិបតី"ឌុណល ត្រម" ដោយសារអ្វីដែលលោកប្រធានាធិបតីថ្មីនេះចង់ធ្វើតាមមហិច្ឆិតារបស់លោក បានត្រូវសភាទប់ស្កាត់បានយ៉ាងគួរឱ្យកក់ក្ដៅ ថាប្រធានាធិបតីអាមេរិកាំងមិនអាចធ្វើអ្វីដែលនាំឱ្យមានគ្រោះថ្នាក់ដល់ពលរដ្ឋគេបានឡើយ។ គេនៅចាំថាៈ លោកប្រធានាធិបតីថ្មីនេះ បានជាប់ឆ្នោតដោយសមត្ថភាពខ្លួនឯង ពុំមានគណបក្សលោកជាអ្នកជួយឱ្យជាប់ឆ្នោតឡើយ ហេតុនេះហើយបានជាការស្នើច្បាប់ទៅសភាមួយចំនួនមិនបានទទួលការគាំទ្រពីសភាវិញ ពីសមាជិកគណបក្សសាធារណរដ្ឋរបស់លោកដែលមានច្រើននៅសភានោះទេ។

-"អូបាមាឃែ" ដែលលោក "ត្រម" ចង់បំបាក់មុខលោកប្រធានាធិបតីមុនដោយ"ស្នើច្បាប់ស្ដីពីសុខភាពថ្មី ទៅលុបច្បាប់អូបាម៉ាឃែ" បានត្រូវបរាជ័យមុនគេ ដោយសមាជិកសភាភាគច្រើន មិនបានទទួលយកទេ -មកទល់ពេលនេះនៅព្យាយាមចង់លុបចោលដដែល តែធ្វើមិនទាន់បាននៅឡើយ ដោយគម្រោងថ្មីរបស់ "ត្រម" មិនទាន់មានអ្វីប្រសើរជាង"អូបាម៉ាឃែ"នៅឡើយ។

-បទបញ្ជាថ្មីរបស់ប្រធានាធិបតី "ឱ្យរឹតបន្តឹងវិធានការណ៍ទប់ស្កាត់អន្តោប្រវេសន៍ខុសច្បាប់" បានត្រូវរដ្ឋចំនួន៩ប្ដឹងបកទៅវិញថា "បានធ្វើបទបញ្ជាផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិក" មិនអាចអនុវត្តន៍បានទេ -នៅរដ្ឋដែលអនុវត្តន៍បទបញ្ជារបស់ប្រធានាធិបតីអនុវត្តន៍បានមានការចុះថយនៃការប្រើពលកម្មតម្លៃថោកនៅការដ្ឋានសំណង់នៅការដ្ឋានកសិកម្មក្នុងការងារធុនទាបនៃពាណិជ្ជកម្ម...។ល។ ប៉ូលិសបានបង្កើនការឆែកឆេរកជនដែលមករស់នៅខុសច្បាប់ធ្វើឱ្យការរំលោភសិទ្ធមនុស្សបានកើនឡើង។ បំណងធំមួយទៀតដែលជាកាសន្យារបស់"ត្រម"គឺសង់ជញ្ជាំងព្រំដែនទប់ស្កាត់អន្តោប្រវេសន៍មកពី "មិកសីកូ"មិនទាន់ធ្វើបានដោយគ្មានប្រភពលុយនៅឡើយ "មិកសីកូ"មិនអាចជួយចេញថ្លៃនោះបានទេ ដូច្នេះត្រូវរកលុយពីប្រភពផ្សេងទៀត។



១០០ថ្ងៃនៃអាណត្តិប្រធានាធិបតីត្រម

ក្នុងរយពេល១០០ថ្ងៃនៃអំណាច"ឌុណល ត្រម"សេដ្ឋវិមាននៅមានទំនាស់យ៉ាងជូរចត់ជាមួយសារពតិមានធំៗ ដូចជា "ស៊ីអិនអិន" ឬ "វ៉ាស៊ីនតោនផូស"ហើយចោទប្រកាន់ដោយប្រើពាក្យថា "ព័តិមានក្លែងក្លាយ-Fake news" ដែលនាំឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៃកម្ពុជាបានគាំទ្រសកម្មភាពនេះ, តែមិនមានការប្ដឹងផ្ដល់គ្នាទេ-ហើយទំនាស់នេះនៅតែបន្តដែលជាប្រភពនៃការចុះប្រជាប្រិយភាពមួយដោយសារប្រជាពលរដ្ឋនៅជឿអង្គភាពសារពតិមានទាំង២នេះថាជាប្រភាពព័តិមានគួរឱ្យជឿបានបំផុតរបស់គេនៅឡើយ។

សេដ្ឋកិច្ចនឹងពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិកដែលមានការកក់ក្ដៅថាលោក"ត្រម" មុខជានាំជំនាញខានសេដ្ឋកិច្ចរបស់លោក មកប្រើដើម្បីលើកដំកើងជីវភាពពលរដ្ឋអាមេរិកាំង, បានផ្ដើមសង្ឃឹមនៅពេល១ខែដំបូង តែមកនៅហ្នឹងថ្លុះបន្ទាប់មកក៏ធ្លាក់ចុះ, ការប៉ុនប៉ងចាប់ហ៊ីឡារី គ្លីងតុន យកទៅដាក់គុកដោយអំពើពុករលួយ **តទៅទំព័រទី០៩**


For your special day...

សម្រាប់ថ្ងៃដ៏ពិសេសរបស់អ្នក



**The UMass Lowell Inn & Conference Center** provides timeless, modern elegance with a relaxing atmosphere.

You and up to 450 guests will be catered to by our attentive staff, while you celebrate in style and comfort.

We offer overnight lodging, scenic outdoor photo opportunities, and a variety of ceremony spaces, including smaller rooms for showers, rehearsal dinners, and engagement parties.

All of our menus can be personalized to suit your individual needs.

សណ្ឋាគារ យូម៉ាសឡូវែលនឹងមណ្ឌលប្រជុំ

ផ្ដល់ជូនយ៉ាងទាន់ចិត្ត ជឿនលឿន សង្ហា ជាមួយនឹងបរិយាកាសយ៉ាងរំភើយ

លោកអ្នកនឹងភ្ញៀវរហូតដល់៤៥០នាក់អាចនឹងជប់លៀង ដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកយើង នៅពេលដែលលោកអ្នកកំពុងរៀបពិធី ប្រកបដោយសម្បូរបែបនឹងយ៉ាងកក់ក្ដៅ ។

យើងផ្ដល់ជូនការស្នាក់អាស្រ័យឆ្លងរាត្រី, ទីធ្លាខាងក្រៅគួរឲ្យរំភើបសម្រាប់ មានឱកាសថតរូបនឹងបន្ទប់សម្រាប់ពិធីការគ្រប់ធុន,

រាប់ទាំង បន្ទប់តូច សម្រាប់បង្កក់កូន, ត្រៀមសម្រាប់ជប់លាងអាហារពេលល្ងាចនឹងពិធី ភ្ជាប់ពាក្យ...។

គ្រប់បញ្ជីមុខម្ហូបអាចនឹងរៀបចំជូនស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗបាន ។

UMASS LOWELL Inn & Conference Center

**UMass Lowell Inn & Conference Center**

50 Warren St., Lowell MA 01852 978-934-6920 877-886-5422 **www.uml.edu/icc**

តមកទំព័រទី ០១

# ចរន្ត២នៃអនាគតវិទ្យាល័យឡូវែល...

លោក វ៉ាស្នា នួន អតីតសមាជិកក្រុម ប្រឹក្សាក្រុងឡូវែលនឹង លោក ដូមីណិក ឡាយ អតីតបេក្ខជនក្រុមប្រឹក្សាសាលារៀនបាន បញ្ចេញយោបល់ថា"គួរតែវិទ្យាល័យកែរលំអរថ្មីនៅកន្លែងដដែល, ចំណែកឯលោក ប៉ាន់ សូ គ្រូបង្រៀននៅវិទ្យាល័យឡូវែលនឹងខ្មែរ ផុសនិយាយថា "គួរតែសង់វិទ្យាល័យថ្មីនៅតំបន់ខលី"។ យោបល់ ចែកគ្នាជា២យ៉ាងនេះ ជាការធ្វើឱ្យក្រុមប្រឹក្សាក្រុងងាយស្រួលនឹង សម្រេចយកខាងណាក៏បាន -តែមាតាបីតាសិស្សមិនច្បាស់ជាទទួល បាននូវវិទ្យាល័យមួយដែលប្រសើរបំផុតសម្រាប់កូននាសតវត្ស ទី២១នេះនៅឡើយទេ។

ដោយសារមកទល់ពេលនេះហាក់ដូចជាមាតាបីតានៅឡូវែល មិនទាន់បានទទួលព័តិមានគ្រប់គ្រាន់សម្រាប់ធ្វើការវិនិច្ឆ័យនៅ


កន្លែងដែលគេរកឃើញថា មានជាតិពុលនៅក្នុងដី អាចនឹងត្រូវគេបិតវិទ្យាល័យជាបន្ទាន់

ឡើយ កាលបរិច្ឆេទក្រុមប្រឹក្សាក្រុងសម្រាប់សម្រេចយកទីតាំង វិទ្យាល័យនេះ បានត្រូវលើកទៅខែ មិថុនាទៅវិញ ទុកឱកាសបន្ថែម បានច្រើនសម្រាប់សិក្សានឹងពិគ្រោះគ្នាឱ្យបានល្អិតល្អន់។

ហេតុអ្វីបានជាមានការផ្តល់ថវិការសម្រាប់ធ្វើវិទ្យាល័យនេះ ឡើងវិញ? គឺកាលពី៣-៤ឆ្នាំ មុនការត្រួតពិនិត្យអាគិសិក្សារបស់ សហព័ន្ធបានឃើញថា "អាគារនេះទ្រុឌទ្រោមមិនគ្រប់លក្ខណះ សុវត្ថិភាពនៃសាលារៀនទេ"រដ្ឋបានចំណាយលុយជាច្រើនលាន រួចហើយសម្រាប់ជួសជុលតែការត្រួតពិនិត្យបន្តរបន្ទាប់នៅឆ្លើយ ថា "មិនគ្រប់លក្ខណះសុវត្ថិភាពដដែល"។ ហេតុនេះហើយបានជា ដោយសារតែ"បញ្ហាសុវត្ថិភាពនេះ សហព័ន្ធបានផ្តល់ថវិការឱ្យធ្វើ សាលានេះ "ថ្មី"ឡើងវិញ ឱ្យស្របតាម "លក្ខណសុវត្ថិភាព" ផង នឹងស្របតាម "លក្ខណបច្ចេកទេសសិក្សាទាន់សម័យ"ផង ការពិត ទៅសាលាចាស់នេះ មិនត្រឹមតែអាចនឹងបាក់រលំទេ តែនៅខ្វះអាគិ ខ្លះទៀតសម្រាប់សិស្សរៀនសូត្រឱ្យបានស្របតាមបច្ចេកទេស សម័យថ្មីទៀតផង។

ការចង់ឱ្យសង់សាលារៀនសាជាថ្មីនេះ បណ្តាលឱ្យមានចរន្ត គំនិតពីធំៗបានកើតឡើង ១-រុះរើសាលាចាស់ធ្វើឡើងវិញឱ្យទៅ ជាថ្មីនៅកន្លែងដដែល ២-រកកន្លែងថ្មីនៅក្នុងឡូវែលសង់វិទ្យាល័យ ទំនើបជំនួសឡើងវិញ។ គំនិតសំខាន់របស់អ្នកដែលចង់បានឱ្យ វិទ្យាល័យឋិតនៅកន្លែងដដែល ហើយគ្រាន់តែកែរលំអឱ្យទៅថ្មីបាន ហើយនោះ គឺចង់ទុកសោភណ្ឌភាពនឹងអនុស្សាវរីយនៃប្រវត្តិសំណង់ ចាស់ឱ្យនៅដដែល ហើយគំនិតធំមួយទៀតរបស់អ្នកដឹកនាំសហគមន៍ គឺដោយសារកូនសិស្សខ្មែរជាច្រើនស្រួលដើរពីផ្ទះទៅសាលារៀនរបស់ ខ្លួនខ្លះបន្ថែមថា "ស្រួលដើរពីសាលារៀនទៅសមាគមខ្មែរ" ដែល នៅមិនឆ្ងាយពីផ្ទះខ្លួននោះទេ។

អ្នកដែលគិតពី"ភាពងាយស្រួល"នេះ ពុំបានគិតដល់ការលំបាក របស់កូននៅពេលមានធ្លាក់ព្រិលមានធ្លាក់ភ្លៀង ឬមានធ្លាក់ខ្យល់ មកលើដំបន់ឡូវែលនោះទេ តើវិបត្តិធម្មជាតិទាំងនេះរាំខានដំណើរ កូនសិស្សប៉ុន្មានដងក្នុងមួយឆ្នាំៗយើងបានដឹងថា ភាពងាយស្រួល នេះរំខានដំបូងបង្អស់គឺ -គ្រាន់តែភ្លៀងធ្លាក់ចុងក្រោយបង្អស់នេះ តែមួយប៉ុណ្ណោះ សិស្សអវត្តមានដល់ទៅ១៤%ទៅហើយ" ម្យ៉ាង ទៀតឃើញកូនសិស្សខ្មែរយើងដើរប្រសេចប្រសាចទាំងហ្វូងៗកាត់ ថ្នល់ជាច្រើនមុននឹងបានមកដល់ផ្ទះសម្បែងតែរៀងៗខ្លួន, រូបភាព នេះបង្ហាញនូវសណ្តាប់ធ្នាប់នឹងការគ្រប់គ្រងតិចជាងកូនសិស្សខ្មែរ ឯទៀតៗ ដែលប្រើរថយន្ត"ប៊ីសលឿង"នាំសិស្សទាំងហ្វូងដូចគ្នា ទៅបង្ហើយកិច្ចការសាលានៅ "Boys & Girls Club" ជាដើម ដែល មានទីតាំងនៅ "ក្រុងខ្មែរ" នៅពេលចេញពីរៀនជាមួយគ្នាការនេះ គឺឆ្លុះបញ្ចាំងពីសុវត្ថិភាពខ្ពស់ផ្តល់នឹងគ្រប់គ្រាន់ឱ្យកូនសិស្សសាលា។

មានបញ្ហាមួយទៀតដែលថាចោទចំពោះថវិការគ្រួសារ គឺការ ប្រើរថយន្តប៊ីស"លឿង"មិនត្រឹមតែមានសុវត្ថិភាពខ្ពស់គួរជាទីទុក ចិត្តទេ ថែមទាំងមិនចំណាយលុយអ្វីទាំងអស់។ ប្រសិនបើលោក អ្នកនៅក្រៅតំបន់ដែលគ្មានប៊ីស"លឿង"នោះរត់ កូនលោកអ្នក ក៏អាចទិញ"ខត"ប្រចាំខែដែលប្រើទៅទីណាក៏បានពេលណាក៏បាន ក្នុងតម្លៃតែ២0ដុល្លាតែប៉ុណ្ណោះ។ មានយោបល់ផ្សេងទៀតថា ដោយ សារការសង់សាលារៀនថ្មី នឹងកូនសិស្សប្រើរថយន្ត "ប៊ីស" គ្រប់ គ្នាដើម្បីទៅវិទ្យាល័យសាលាក្រុងនឹងតម្លើង"តាក់"ដែលនឹងប៉ះពាល់ ដល់ថវិការគ្រួសារ **តទៅទំព័រទី ០៨**



# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។




ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :

- រស់នៅផ្ទះរដ្ឋ

អាយុ ២២ ឆ្នាំឡើងទៅ

- មាសហ៊ែលស្តង់ដា

**ផលប្រយោជន៏ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការ រស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក ២៤ម៉ោង

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្តានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**

To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

# សមាគមអង្គរវត្តតវ៉ាឱ្យបញ្ឈប់ការតែងតាំងឯកអគ្គរដ្ឋទូតបារាំងនៅកម្ពុជា

ថ្ងៃទី ១៤ ខែមេសា ២០១៧

ឯកឧត្តម ហ្វ្រង់ស្វ័រ ហុល្លង់

ប្រធានាធិបតីនៃសាធារណរដ្ឋបារាំង

វិមានប្រធានាធិបតី អេលីហ្សេ

55, Rue du Faubourg Saint-Honoré 75008 PARIS

**កម្មវត្ថុ :** ជំទាស់ការតែងតាំងអគ្គរដ្ឋទូត អេវ៉ា ង្វៀងប៊ិញ

ឯកឧត្តមប្រធានាធិបតី ហ្វ្រង់សូវ ហុល្លង់ ជាទីគោរព !

តាងនាមយើងខ្ញុំជាតំណាងប្រជាពលរដ្ឋបារាំងដែលមានដើមកំណើតខ្មែរ រាប់សែននាក់នៅប្រទេសបារាំង និងខ្មែរនៅប្រទេសខ្មែរ ហើយនឹងខ្មែរនៅពិភពលោកទាំងមូលយើងខ្ញុំសូមផ្ញើរសារមួយនេះជូនលោកដើម្បីសុំណូមពរលោកមេត្តាអនុគ្រោះពិនិត្យមើលសាជាថ្មីអំពីការតែងតាំងលោកស្រី អេវ៉ា ង្វៀងប៊ិញ ជាឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ការតែងតាំងដែលបានរៀបចំឡើងយ៉ាងហ្មត់ចត់មុនពេលដែលលោកនឹងបញ្ចប់អាណត្តិប្រធានាធិបតីនេះ បណ្តាលឱ្យមានភាពប្រឆាំងគោលការណ៏យ៉ាងជាក់ស្តែង ដោយសារបុព្វហេតុប្រវត្តិសាស្ត្រ និងផ្នែកការទូត ដែលប្រទេសបារាំង និងលោកដែលជាអ្នកដឹកនាំពិតជាអាចយល់យ៉ាងច្បាស់ណាស់ ។ ប្រទេសវៀតណាមបានឆ្លៀតឱកាសនៅពេលឈ្លានពានប្រទេសខ្មែរ( ការឈ្លានពានដែលប្រទេសបារាំង និងមហាអំណាចផ្សេងៗទៀតបានថ្កោលទោសយ៉ាងម៉ឹងម៉ាត់) បញ្ជូនពលរដ្ឋវៀតណាមមួយចំនួនធំមករស់នៅដោយខុសច្បាប់ក្នុងប្រទេសខ្មែរ ក្នុងគោលបំណងធ្វើឱ្យមានការប្រែប្រួលក្នុងចំនួនប្រជាជាតិខ្មែរ ដែលអាចនាំឱ្យមានផលពិបាកមួយចំនួនដែលយើងមិនត្រូវការ ។ ហើយវៀតណាមក៏បានបង្ខំឱ្យប្រទេសខ្មែរទទួលយកសន្ធិសញ្ញាលើព្រំដែនមិនស្មើភាពមួយចំនួនផងដែរ ។ បញ្ហាព្រំដែននេះ បានធ្វើឱ្យមានភាពតានតឹងយ៉ាងច្រើនរវាងវៀតណាម និងកម្ពុជា ។ ប្រទេសខ្មែរ និងប្រទេសវៀតណាមបានស្នើសុំជំនួយបច្ចេកទេសពីប្រទេសបារាំងដើម្បីពិនិត្យមើលបន្ទាត់ព្រំដែន។ ដូច្នេះក្នុងឋានៈជាមហាអំណាច និងប្រទេសដែលការពារសិទ្ធិមនុស្សនិងបុរីជន តើប្រទេសបារាំងត្រូវធ្វើយ៉ាងណាដើម្បីកុំឱ្យមានភាពលំអៀងក្នុងបញ្ហាស្មុគស្មាញនេះ?



## Colère contre la France à Phnom Penh

La nomination, le 28 février dernier en Conseil des ministres, d'une Française d'origine vietnamienne, Eva Nguyen Binh, au poste d'ambassadeur de France à Phnom Penh provoque la fureur des autorités cambodgiennes. Le Vietnam et le Cambodge connaissent depuis des années des relations fort tumultueuses. De plus, les deux pays sont actuellement en négociations serrées pour le tracé de leurs frontières. Dans ce cadre, le Cambodge a demandé l'aide technique de la France. Le choix de la jeune femme, précédemment en poste à Hanoï, vient remettre gravement en cause cette confiance.

នេះជាអត្ថបទកាសែតហ្វីការ៉ូ កំហឹងប្រឆាំងនឹងបារាំងនៅភ្នំពេញ -ស្តីអំពីការតែងតាំងឯកអគ្គរដ្ឋទូតថ្មីនៅស្ថានទូតបារាំងភ្នំពេញ



លោកស្រីឯកអគ្គរដ្ឋទូតបារាំងនៅកម្ពុជាដើមកំណើតវៀតណាម

យោងទៅតាមប្រវត្តិសាស្ត្រប្រជារាស្ត្រខ្មែរដែលតែងតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹង ប្រទេសបារាំង នៅចងចាំជានិច្ចនាមរបស់ប្រមុខរដ្ឋបារាំង ដូចជាស្តេចណាប៉ូឡេអុងទី៣ ដែលបានបញ្ឈប់ការលេបទឹកដីខ្មែរអំពីសំណាក់ប្រទេសវៀតណាម ដែលពេលនោះហៅថា អណ្ណាម និងប្រទេសថៃ ដែលពេលនោះហៅថាសៀម ។ នៅឆ្នាំ១៩៦៦ ឧត្តមសេនី ស្យាក ដឺហ្គោល ដែលជាមហាបុរសបារាំងម្នាក់ បានថ្លែងសន្ទរកថា មួយនៅក្នុងពហុកីឡាដ្ឋានអូឡាំពិក ដែលបានបង្ហាញថាប្រទេសបារាំងមានភាពជាប្រទេសមហាអំណាច និងដែលប្រកាន់ភាពយុត្តិធម៌ជាថ្មីម្តងទៀត ។ ហើយបន្ទាប់មកទៀត លោកប្រធានាធិបតី ហ្វ្រង់ ស្វ័មីទារ៉ង់ដ៏ក៏បានធ្វើឱ្យមហាអំណាចមួយចំនួនព្រមចុះហត្ថលេខាគាំទ្រកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅថ្ងៃទី២៣តុលា ឆ្នាំ១៩៩១ ។ នៅក្នុងបរិបទនេះ ការរក្សាទុកលោកស្រី អេវ៉ា ង្វៀន ប៊ិញ ជាឯកគ្គរដ្ឋទូតនៃប្រទេសបារាំងនៅព្រះរាជាណាចក្រកម្ពុជា មិនមែនគ្រាន់តែជាការប្រមាថដល់ប្រជារាស្ត្រខ្មែរប៉ុណ្ណោះនោះទេ តែក៏ជាការបំពានទៅលើកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីសផងដែរ ។ យើងខ្ញុំជឿជាក់យ៉ាងខ្លាំងថា សតិសម្បជ្ជញ្ញៈរបស់លោកដែលជាប្រមុខរដ្ឋដ៏ធំម្នាក់មិនបណ្តោយឱ្យមាននាមរបស់លោកជាប់នៅក្នុងទំព័រប្រវត្តិសាស្ត្រដ៏កំសត់ដូចពេលដែលសភាជាតិបារាំងក្រោមការដឹកនាំនៃលោក វ៉ាំងសង់ អ៊ីរីយ៉ូល បានប្រគល់ទឹកដី( កម្ពុជាក្រោម) កូសាំងស៊ីនដែលមានពលរដ្ឋខ្មែររាប់លាននាក់ ទៅឱ្យប្រទេសវៀតណាមធ្វើឱ្យរាស្ត្រដែលនៅទឹកដីរបស់ដូនតាខ្លួនក្លាយទៅជាប្រជាពលរដ្ឋដែលមានតម្លៃមិនស្មើជនជាតិយួននោះឡើយ ។

ឯកឧត្តមប្រធានាធិបតីជាទីគោរពជាថ្មីម្តង ទៀត ប្រជានុរាស្ត្រខ្មែរទាំងអស់សូមសុំណូមពរដល់លោកមេត្តាអនុគ្រោះពិនិត្យសារឡើងវិញ ចំពោះការតែងតាំងឯកអគ្គរដ្ឋទូតនេះផង ។

ឯកឧត្តមប្រធានាធិបតី យើងខ្ញុំសូមផ្ញើក្តីសង្ឃឹមទៅលើភាពថ្លៃថ្នូរ និងសតិសម្បជ្ជញ្ញៈរបស់លោកដែលជាអ្នកដឹកនាំដ៏ឆ្នើមម្នាក់ ថានឹងអាចជួយដោះស្រាយបញ្ហានេះ បានជាមិនខាន ។

ដោយសេចក្តីគោរពរាប់អានខ្ពង់ខ្ពស់ អំពីយើងខ្ញុំទាំងអស់គ្នា តំណាងប្រជានុរាស្ត្រខ្មែរ !

សាគូ សាមុត

ប្រធានសមាគមអង្គរវត្ត នៅស្រុកបារាំង


# ការិយាល័យច្បាប់

## រ៉ូសា និង តាំង



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.
មេធាវី អែន ទ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

| SERVICES | តំណាងក្តីដូចខាងក្រោម |
| --- | --- |
| • Auto Accidents/ Personal Injury | • គ្រោះថ្នាក់រថយន្ត/ របួសរូបរាង់កាយ |
| • Bankruptcy | • ក្ស័យធន |
| • Immigration | • អន្តោប្រវេសន៍ |
| • Consumer Protection | • ការពារអតិថិជន |
| • Real Estate Closings/Disputes | • ទំនាស់ផ្នែកអចលនវត្ថុ |
| • Divorces Child Custody | • លែងលះ និងអាណាព្យាបាលកិច្ច |

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | at@rosataing.com

# ការិយាល័យ មេធាវី ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៏
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ **978-459-5000 or 800-308-3766**
www.thomasinlowell.com

# ភ្នាក់ងារជ្រើសរើសបុគ្គលិក

កំពុងត្រូវការបុគ្គលិកចំនួន១០-២០នាក់ឡើងទៅ សម្រាប់ការងារវេនថ្ងៃ និងយប់ ដើម្បីធ្វើការក្នុងក្រុមហ៊ុនផ្លាស់ស្ទិចនៅ Leominster ។ អ្នកមានបទពិសោធន៏គឺកាន់តែប្រសើរ ។ នឹងមានផ្តល់ជូននូវរយន្តដឹកជញ្ជូនទៅវិញទៅមកសម្រាប់ធ្វើការ ។ ត្រូវអាចធ្វើការងាររយៈពេល ១២ ម៉ោងក្នុងមួយវេន, ៣ ទៅ ៤ ថ្ងៃ ក្នុងមួយសប្តាហ៏, និងត្រូវធ្វើការងាររហ័សរហួន ។ ប្រសិនបើចាប់អារម្មណ៏

សូមទំនាក់ទំនងមកលេខទូរស័ព្ទ **215-317-7932**

( ភាសាវៀតណាម និងអង់គ្លេស(រឺ **774-641-6013**) ភាសាខ្មែរ

# ព្រះសង្ឃខ្មែរកំពុងធ្វើការស្រាវជ្រាវនៅសាកលវិទ្យាល័យ“ហាវឺដ”

**ដោយ ពិន សំខុន**

**ឡូវែល:** ព្រះសង្ឃខ្មែរមួយអង្គព្រះនាម ព្រះឧបាលិវង្ស យ៉ន សេងយាត ព្រះជន្ម៣៩វស្សា គង់ប្រចាំវត្តឧណ្ណាលោមព្រះអង្គមានតួរនាទីជាអនុប្រធានពុទ្ធិកមហាវិទ្យាល័យភ្នំពេញបាននិមន្តមកបន្តការសិក្សានាដើមឆ្នាំ២០១៧នេះនៅសាកលវិទ្យាល័យដ៏ល្បីល្បាញមួយនាសហរដ្ឋអាមេរិក សាកលវិទ្យាល័យ"ហាវឺដ"(សាលាហាវឺដទេវវិទ្យា -Harvard Divinity School) ដែលជាករណីកម្របំផុតសម្រាប់ប្រទេសកម្ពុជា។

ព្រះអង្គ សេងយ៉ាត កំពុងធ្វើការសិក្សាស្រាវជ្រាវធ្វើនិក្ខេបបទរយៈពេល១៤ខែ ក្នុងកម្មវិធីសិក្សាបន្ទាប់ពីក៏រឹតបណ្ឌិត (Post Doctrate Fellowship) សញ្ញាប័ត្របណ្ឌិតដែលព្រះអង្គបានទទួលនៅសាកលវិទ្យាល័យសេរីលង្កាពេលនេះព្រះអង្គស្រាវជ្រាវក្នុងប្រធានបទ"ជីវិតសម្តេចមហាឃោសនន្ទ វ៉ា យ៉ាវ ក្នុងដំណោះស្រាយសន្តិភាពតាមព្រះពុទ្ធសាសនានៅកម្ពុជា"។

ខ្មែរផុសស.រ.អា.បានជួបសម្ភាសន៏ជាមួយព្រះអង្គ យន សេងយ៉ាត កាលពីថ្ងៃទី៧មេសាកន្លងទៅនេះនៅឡូវែល:

**ខ្មែរផុសស.រ.អា:** ហេតុអ្វីក៏ព្រះជ្រើសយកប្រធានបទនេះសម្រាប់ការស្រាវជ្រាវរបស់ព្រះអង្គ?

**ព្រះអង្គ យន សេងយ៉ាត :** អាត្មាជ្រើសយកប្រធានបទនេះជាមួយលោកគ្រូជាមេប្រយោគរបស់មហាវិទ្យាល័យដោយយល់ឃើញថា "ព្រះអង្គមហាឃោសនន្ទបានជួបសិក្សាច្រើនពីគម្រូរបស់មហាត្ម័គន្ធី នៃប្រទេសឥណ្ឌា, ព្រះអង្គផ្តើមធ្វើធម្មយាត្រាដើម្បីសន្តិភាពនៅកម្ពុជាពីឆ្នាំ១៩៩២ដល់១៩៩៧, ដោយព្រះអង្គយល់ថា កិច្ចព្រមព្រៀងក្រុងប៉ារីសជាការចុះសម្រុងគ្នាតាមផ្លូវច្បាប់តែកំហឹងនៅពោរពេញក្នុងខ្លួននៃគូរភាគីជម្លោះនៅឡើយ ដូច្នេះនៅមានការចុះសម្រុងរំងាប់កំហឹងផ្លូវចិត្តថែមទៀតទើបបានជោគជ័យ, រីឯព្រះសង្ឃនៅតែវត្តអារាមបើនៅរំងាប់ជម្លោះតែក្នុវត្តទេ នឹងមិនមានប្រសិទ្ធភាពទេ, ដូច្នេះព្រះសង្ឃត្រូវចេញទៅទីតាំងប្រជាពលរដ្ឋបង្ហាត់បង្ហាញបិណ្ឌបាត ពីការជានាគ្នាដោយសណ្តោសមិនចងពៀរនឹងគ្នាគ្មាននរណាជាអ្នកឈ្នះ ហើយក៏គ្មានអ្នកចាញ់ដែរ...នេះហើយជាគម្រូនៃសន្តិភាពដែលព្រះពុទ្ធសាសនាផ្តល់ដល់កម្ពុជានឹងសម្រាប់ប្រើក្នុងតំបន់ផ្សេងៗទៀតក្នុពិភពលោកផង" ...

**ខ្មែរផុសស.រ.អា:** មានធម្មយាត្រាព្រះអង្គ


ព្រះតេជគុណ យន សេងយ៉ាត

មហាឃោសនន្ទខ្លះធ្វើទៅប្រកបដោយភាពគ្រោះថ្នាក់ខ្លាំងណាស់, តើព្រះអង្គមានដែលចូលរួមដំណើរធ្វើធម្មយាត្រានោះដែរឬទេ?

**ព្រះអង្គ យន សេងយ៉ាត:** អាត្មាធ្លាប់ចូលរួមដែរ កាលពីនៅក្មេងដោយសារចូលចិត្តតែមិនយល់ពីអត្ថន័យនៃធម្មតាត្រានោះ បានន័យថា អ្វីនោះទេ, អាត្មាចាំថាពេលបានទៅដល់តំបន់ខ្មែរក្រហមជួបលោក អៀង សារី ក៏ព្រះអង្គឥតមានឱ្យនរណាខុសនរណាត្រូវអ្វីទេ មានតែបិណ្ឌបាទការខឹងគ្នាទៅវិញទៅមកអត់ឱនឱ្យគ្នាតែប៉ុណ្ណោះ...

**ខ្មែរផុសស.រ.អា:** គឺព្រះអង្គបញ្ចុះបញ្ចូលឱ្យទទួលយកនូវការជានាគ្នាដោយស្ម័គ្រចិត្តខ្លួនឯង មែនដែរឬទេ?

**ព្រះអង្គ យន សេងយ៉ាត:** ពរ នេះហើយជាការជានាគ្នាដោយផ្លូវចិត្ត...

**ខ្មែរផុសស.រ.អា:** មុនពេលព្រះមហាឃោសនន្ទសុគតទៅព្រះអង្គបានគង់នៅវត្ត "ហ្វីឡាដែលហ្វៀ" បន្ទាប់មកលោកទៅគង់នៅវត្ត"អំហឺ", តើព្រះអង្គមានបានទៅមើលកន្លែងដែលព្រះមហាឃោសនន្ទរស់នៅនាសហរដ្ឋអាមេរិកជាចុងក្រោយដែរឬទេ? មានបានឯកសារអ្វីខ្លះពីដំណើរទៅទីទាំងនោះទេ?

**ព្រះអង្គ យន សេងយ៉ាត:** -មានដែរ តែច្រើនទទួលតែពាក្យចចាមអារាមដែលអាត្មាប្រើមិនបាន, អាត្មាគ្រាន់តែដឹងថា ជីវិតចុងបញ្ចប់របស់ព្រះអង្គវេទនាណាស់ ដោយព្រះអង្គខ្វះអ្នកថែទាំក្នុងនាមជាមនុស្សចាស់ជរា...

**ខ្មែរផុសស.រ.អា:** តើនៅសាលារៀនសហរដ្ឋអាមេរិកព្រះអង្គមានអារម្មណ៏នឹងការកត់សំគាល់យ៉ាងណាដែរ?

**ព្រះអង្គ យន សេងយ៉ាត:** អាត្មារីករាយណាស់ ដែលបានមកស្រាវជ្រាវនៅ "មហាវិទ្យាល័យហាវឺដ"នេះ, បានជួបនឹងអ្នកប្រាជ្ញឯទៀតជាច្រើន មកពីច្រើនប្រទេសនានានៃសាកលលោក, នៅក្នុងសាលាដែលអាត្មារៀននោះ តែហៅថា "សាលទេវ - Divinity School" គេក៏មកស្រាវជ្រាវដូចយើងដែរ,...គ្រូៗយើងមានចរឹកស្លូតបូតមិនដូចស្រុកអាស៊ីយើងសិស្សត្រូវតែគោរពគ្រូថាស្តីឱ្យសិស្សអ្វីក៏បាននោះទេ គឺគេគោរពគ្នាទៅវិញទៅមកស្មើរគ្នាគ្រូជាអ្នកចេះពិតប្រាកដច្បាស់លាស់ ដូចជាភាសាបាលី ភាសាឥណ្ឌាជំនាន់ "ព្រះបាទធម្មាសោក" កាលពី២០០០ឆ្នាំមុន ក៏គេចេះដែរចង់រកសៀវភៅអ្វីក៏មានដែរ មានរាប់លានក្បាលដែរសិស្សអាចមើលឬចម្លងយកមកប្រើប្រាស់មិនមានខ្វះទេ...សិស្សគេទៅរៀនដោយប្រឹងប្រែងដោយចង់ចេះចង់ដឹងមិនចាំបាច់នរណាប្រៀនប្រដៅគេទេ, កម្មវិធីរៀននៅសាលាមានតាំងពីម៉ោង៩ព្រឹកដល់ម៉ោង៩យប់ គ្មានឈប់ឈរទេកូនសិស្សមករៀនពេញៗរាល់ថ្ងៃ ។

**ខ្មែរផុសស.រ.អា:** ព្រះអង្គជាសង្ឃអីចឹងទៅរៀននៅសាលាមានស្រីមានប្រុស តើមានកន្លែងអ្វីពិសេសសម្រាប់ព្រះអង្គជាព្រះសង្ឃដែរឬទេ?

**ព្រះអង្គ យន សេងយ៉ាត: ពរ!** អត់មានអ្វីពិសេសពីគេទេ, ពេលឆាន់ទៅយកម្ហូបអាហារដោយខ្លួនឯងទៅអង្គុយតុរួមឆាន់អាហារជាមួយគេឯងមិនមានអ្វីខុសពីគេទេ!

**ខ្មែរផុសស.រ.អា:** តើមានចង្ហាន់ខ្លះ ដូចចង្ហាន់ដែរព្រះអង្គធ្លាប់ឆាន់ដែរឬទេ?

**ព្រះអង្គ យន សេងយ៉ាត:** ពរ អត់មានទេបានប្អូន(ចង្អុលទៅព្រះសង្ឃមួយអង្គដែលនៅក្បែរ) គេនាំមកឡូវែលម្តងៗ ពេលសម្រាកចូលរួមបុណ្យទានទៅ ក៏បានចង្ហាន់ស្រុកយើងខ្លះទៅ!

**ខ្មែរផុសស.រ.អា:** តើព្រះអង្គនិមន្តមកនេះមានអាហារូបករណ៏ ការឧបត្ថម្ភការសិក្សានៅសហរដ្ឋអាមេរិកយ៉ាងណាដែរ?

**ព្រះអង្គ យន សេងយ៉ាត:** អាត្មាមកនេះដោយញាតិញោមគេឧបត្ថម្ភឱ្យមករៀនមិនមានអាហារូបករណ៏ពិអាមេរិក ឬពីរដ្ឋាភិបាលកម្ពុជាទេ, សាលាបានអនុញ្ញាត្តិឱ្យមករៀនសូត្រនៅ"ហាវឺដ" ក៏ឆក់យកឱកាសមករៀនទីនេះទៅ!

**ខ្មែរផុសស.រ.អា:** ខ្ញុំព្រះករុណាអរព្រះគុណហើយនឹងសុំអនុញ្ញាត្តិធ្វើសម្ភាសន៏ជាមួយព្រះអង្គនៅពេលក្រោយទៀត ។

**ព្រះអង្គ យន សេងយ៉ាត:** ពរ





Do you want Lowell High School to be:
- 100% new & modern high school?
- Most efficient and effective for best learning?
- Safe and without disruption to learning?
- A more collaborative, campus setting?

**Say Yes to LHS at Cawley**

Make your voice heard!
Send a text to **(978) 905-0663**
or
email us at citizensforcawley@gmail.com

តើលោកអ្នកចង់ឲ្យសាលាឡូវែលហាយស្កូល :
- ជាវិទ្យាល័យថ្មី និងទំនើប 100% រឺ?
- កាន់តែប្រសិទ្ធិភាពបំផុត សម្រាប់ការរៀនសូត្រដ៏ប្រសើររឺទេ?
- មានសុវត្ថិភាព និងគ្មានការរំខានដល់ការសិក្សារឺយ៉ាងណា?
- កាន់តែមានការចូលរួម និងមានការកំណត់ទីតាំងដែររឺទេ?

**និយាយថា យល់ព្រម ចំពោះសាលាឡូវែលហាយស្កូលនៅ** Cawley
ចូលរួមបញ្ចេញមតិយោបល់របស់លោកអ្នក!
សូមផ្ញើសារមកកាន់លេខ **(978) 905-0663**
រឺ
អ៊ីម៉ែលមកយើងខ្ញុំតាមរយៈ: citizensforcawley@gmail.com



## ការវិភាគ

របស់ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណ

### ការសម្លាប់អ្នកចេះដឹងនឹងនាំឲ្យប្រទេសទន់ខ្សោយ

ការធ្វើឃាតអ្នកចេះដឹងដែលជួយបំភ្លឺបញ្ហាសង្គម ដូចលោកកែមឡីជាដើម បើចេះតែមានជាបន្តទៅទៀត នឹងធ្វើឲ្យប្រទេសកម្ពុជាដែលទន់ខ្សោយស្រាប់នឹងចុះខ្សោយថែមទៀត។ នៅប្រទេសប្រជាធិបតេយ្យដែលគោរពច្បាប់ទម្លាប់និងគោរពសិទ្ធិមនុស្ស គេជម្រុញឲ្យមានអ្នកចេះដឹងច្រើន រហូតទទួលអ្នកចេះដឹងពីបរទេសថែមទៀត ព្រោះអ្នកចេះដឹងនេះហើយ ដែលធ្វើឲ្យប្រទេសបានសុខសន្តិភាពនិងចំរើនលូតលាស់។ ពីមុន គេឮសូរតែពួកកុម្មុយនិស្តសម្លាប់ពួកបញ្ញវ័ន្តដោយខ្លាចក្រែងសើរើមាត់បក្ស។ អាណានិគមនិយមបរទេសដែលត្រួតត្រាប្រទេសណា តែងសម្លាប់ម្ចាស់ស្រុកដែលជាអ្នកស្នេហាជាតិប្រឆាំងនឹងការត្រួតត្រា។ របបផ្តាច់ការតែងសម្លាប់អ្នកប្រឆាំងដើម្បីការពារអំណាច។ល។ ប្រទេសកម្ពុជាបានឆ្លងកាត់សេចក្តីទុក្ខសោកជាយូរមកហើយ ទោះសម្លាប់ដោយផ្លូវនយោបាយក្តី ពុំមែននយោបាយក្តី ជាហេតុពុំល្អសម្រាប់ប្រទេសរបស់ខ្លួន។ ពលរដ្ឋខ្មែរបានឆ្លងកាត់របបទាំងអស់ដូចពោលមកនេះ។ អង្គការសហប្រជាជាតិបានមកជួយរៀបចំឲ្យប្រទេសកម្ពុជាបានសុខសន្តិភាព ដោយឲ្យបរទេសដកកម្លាំងទាំងអស់ចេញពីប្រទេសកម្ពុជា ហើយខ្មែរនិងខ្មែរបានព្រមព្រៀងគ្នា អនុវត្តរបបប្រជាធិបតេយ្យសេរីពហុបក្ស ប៉ុន្តែការអនុវត្តពុំបានត្រឹមត្រូវតាមកិច្ចព្រមព្រៀងនោះឡើយ នៅមានការរំលោភសិទ្ធិមនុស្ស ការលួចសម្លាប់គ្នា លោកជាវិជ្ជា លោកឈុតវុទ្ធី ហើយពេលនេះលោកកែមឡីជាដើម។

ព្រះពុទ្ធបានបង្រៀនមនុស្សកុំឲ្យកាប់សម្លាប់គ្នារហូតហាមមិនឲ្យសម្លាប់សត្វតិរច្ឆាន គឺឲ្យតែសត្វមានជីវិតហាមមិនឲ្យសម្លាប់ទាំងអស់ ដូចក្នុងសិក្ខាបទទី១នៃសីល៥។ មិនត្រឹមតែសត្វមានវិញ្ញាណទេ ក្នុងព្រះវិន័យរបស់ភិក្ខុសង្ឃ ព្រះពុទ្ធហាមមិនឲ្យភិក្ខុជីកដីកាប់ដើមឈើ ភិក្ខុណាប្រព្រឹត្តត្រូវអាបត្តិបាចិត្តិយៈ។ ព្រះពុទ្ធបានបង្រៀនជាគ្រឿងឧបមាចំពោះសត្វជាមួយខ្លួនថា ខ្លួនស្រឡាញ់ជីវិតចង់ជួបជុំក្រុមគ្រួសារបងប្អូនកូនចៅយ៉ាងណា មនុស្សសត្វដទៃក៏មានលក្ខណៈដូចគ្នា ដូច្នេះមិនត្រូវបៀតបៀនមនុស្សសត្វឡើយ។

ត្រូវរកការពិតអ្នកសម្លាប់លោកកែមឡី ប៉ុន្តែមិនត្រូវមួលបង្កាច់អ្នកដែលគេមិនបានប្រព្រឹត្តក្នុងល្បិចស្វាស៊ីបាយមកលាបមាត់ពពែ។កម្ពុជាមានឈ្មោះអាក្រក់ណាស់ក្នុងឆាកអន្តរជាតិ ដូច្នេះត្រូវសម្រួលគ្នារៀបចំបោះឆ្នោតដោយសេរីនិងយុត្តិធម៌ក្នុងឆ្នាំ២០១៧-៨៕

វត្តខ្មែរកាណាដា,ថ្ងៃ២១មេសា២០១៧ ;www.hoksavann.org;savannhok@yahoo.com

## តមកពីទំព័រទី ០៤ ចរន្ត២នៃអនាគតវិទ្យាល័យឡូវែល...

-ការនេះយើងគួរគិតថា "តាក់" អាចនឹងឡើង៥០ដុល្លាក្នុងមួយឆ្នាំមែន តើយើងមិនគួរសន្សំលុយតិចតួចនេះ លើតម្លៃសិក្សានឹងសុវត្ថិភាពរបស់កូនទេ ហើយប្រសិនបើកណ្តាលក្រុងឡូវែលនឹងក្លាយជាក្រុង"ពាណិជ្ជកម្ម"ទៅវិញ នៅពេលដែលវិទ្យាល័យចេញទៅនៅក្រៅក្រុងពេលនោះសាលាក្រុងអាចនឹងយកបានតាក់ច្រើនជាង៥០ដុល្លា ដែលលោកអ្នកចាយសម្រាប់ការរៀនសូត្រនឹងជិះ"បឺស"របស់កូនទៀតផង។

ចុះបើគំនិតថា"សាលាត្រូវដកចេញពីកណ្តាលក្រុង"នេះត្រឹម ត្រូវហើយស្របនឹងបច្ចេកសិក្សាធិការហើយ តើហេតុអ្វីក៏សាលាក្រុងនៅតែស្នើរយោបល់ឱ្យមានការបែងចែកខ្វែងយោបល់ធ្វើអ្វី? ម្ចាស់លុយគេចង់ឃើញ"សាលាសង់ថ្មីនៅកន្លែងថ្មី" បើរកមិនបាន ទើបឱ្យកែរឆ្នៃនៅកន្លែងដើមតែនេះជាជម្រើសទី២ទេ។ នៅស្រុកអាមេរិកនេះថ្វីត្បិតតែច្បាប់ប្រកាន់ពូជសាន៏បានលុបចោលទៅជាយូរហើយក្តី ក៏នៅមានអាមេរិកកាំងខ្លះចង់រក្សា"ភាពខ្ពង់ខ្ពស់ជាងសាសន៏ដ៏ទៃ"ច្រើននៅឡើយ គេមិនចង់ឃើញមានសាសន៏ដ៏ទៃចូលឡូកឡំទៅកាន់តំបន់"ថ្លៃថ្នូរ"របស់គេទេ-យកសាលាចេញពី "ហាឡិន" ទៅកាន់"បែលវឺឌ្យេ" គឺនាំសិស្សគ្រប់ជាតិសាសន៏ទៅកាន់ទីនោះ ហេតុនេះហើយបានជាជម្រើសទី២ បានក្លាយទៅជាទី១ ដោយសារនៅសាលាក្រុងមានសមាជិកនៃក្រុមប្រឹក្សាក្រុងមានអ្នកដែលរស់នៅ"បែលវឺឌ្យេ" ដល់ទៅ៦រូបក្នុងចំណោម៩។ ហេតុនេះហើយដែលធ្វើឱ្យយើងយល់ថា ហេតុអ្វីបានជាលោកអតីតសមាជិកក្រុមប្រឹក្សាក្រុងឡូវែលសញ្ជាតិខ្មែរ វាស្នា នួន និយាយកាលពី២សប្តាហ៍មុននោះថា "អ្វីៗបានសម្រេចរួចទៅហើយ"នោះ។

សហគមន៏យើងគួរស្វែងរកឱកាសនិយាយគ្នារកមូលហេតុដើម្បីចុះសម្រុងគ្នាដើម្បីទាញយកការសិក្សាដែលប្រសើរបំផុត សម្រាប់កូនរៀនបង្ហាញទស្សនៈឱ្យបានមុនពេលដែលក្រុមប្រឹក្សាក្រុងធ្វើការសម្រេចចិត្តជាចុងក្រោយ។ យើងធ្លាប់ធ្វើការបានសម្រេចជោគជ័យច្រើនហើយ យើង"ធ្វើបានខ្លាំងពីព្រោះយើងធ្វើត្រូវ ធ្វើទៅវាមានន័យ" ដូច្នេះយើងបន្តពិគ្រោះគ្នាឱ្យបានឆាប់ជាទីបំផុត គឺយើងបានរៀបអនាគតសម្រាប់១០០ឆ្នាំទៅមុខនៃសហគមន៏យើង៕




# បោះឆ្នោតនៅប្រទេសបារាំងបានលទ្ធផលចម្លែកនៅជុំទី១

**ដោយ ពិន សំខុន**

នៅប្រទេសបារាំងដែលសម្បូរពលរដ្ឋដើមកំណើតខ្មែរ ច្រើនជាងគេបង្អស់នៅទ្វីបអឺរ៉ុបរស់នៅ, បេក្ខជន១១នាក់ឈរឱ្យពលរដ្ឋបារាំងបោះឆ្នោតជាប្រធានាធិបតីរបស់ខ្លួន កាលពីថ្ងៃទី២៣ មេសា ២០១៧ នាជុំទី១។

ពលរដ្ឋបារាំងបានជ្រើសយកបេក្ខជន២រូបដែលមានលក្ខណៈចម្លែក ១-អេម៉ានុអែល ម៉ាក្រុង អាយុ៣៩ឆ្នាំ ពុំមានបទពិសោធធ្លាប់ឈរឈ្មោះជាអ្នកនយោបាយម្តងណានៅឡើយទេ ជាបេក្ខជនគណបក្ស"ឯករាជ្យកណ្តាល-Indepedant Centriste" - បានឆ្នោត២៣%២- ម៉ារីន ឡឺប៉ែន បេក្ខនារីមកពីគណបក្ស"Front National" ជាគណបក្សស្តាំផុត មាននិន្នាការប្រកាន់ពូជសាសន៍ តឹងតែងប្រឆាំងនឹងអន្តោប្រវេសន៍មជ្ឈឹមបូពា គេតែងរាប់បញ្ចូលគណបក្សនេះទៅនឹងចរន្ត"ណាស៊ី"របស់អល្លឺម៉ង់បានឆ្នោត២១%។ ហេតុដ៏ចម្លែកនោះគឺគណបក្សធំៗ ដែលធ្លាប់ធ្វើនយោបាយល្បីៗយូរយាមកហើយបានរបូតចេញអស់ បែរជាជ្រើសយកអ្នកដែលមិនមានប្រជាប្រិយភាពនឹងអ្នកដែលគេធ្លាប់ដាក់ចោលនៅក្បៀនជញ្ជាំងមកជំនួសវិញ, បានន័យថា "បារាំងបានសម្តែងការជិនឆ្អន់នឹងរបៀបធ្វើនយោបាយជំនាន់ចាស់ចង់ផ្លាស់ប្តូរទៅជាចរន្តថ្មីស្រឡាងមួយផ្សេងទៀត"។

គេអាចសង្ស័យថា តើចលនានៅប្រទេសបារាំងមានលំនាំដូចការបោះឆ្នោតចុងក្រោយនៅចក្រភពអង់គ្លេស ឬក៏ដូចនៅសហរដ្ឋអាមេរិកដែរឬទេ? ប្រទេសបារាំងមានការលំបាកនឹងនឹងគ្រប់គ្រងសេដ្ឋកិច្ចរបស់ប្រទេសខ្លួនឱ្យមានលំនឹងជាច្រើនឆ្នាំមកហើយៗម្យ៉ាងទៀត ក៏មិនអាចបង្ហាញនូវការរក្សាសន្តិសុខជូនពលរដ្ឋខ្លួនបានផង, ការរងគ្រោះរបស់បរាំង ដោយភេរវកម្ម "អាយស៊ីស"ដ៏ធ្ងន់ធ្ងរកាលពីឆ្នាំមុន ហើយនឹងនៅឆ្នាំនេះមុនពេលបោះឆ្នោតតែ១ថ្ងៃ ភេរវករ "អាយស៊ីស" បានបាញ់សម្លាប់ប៉ូលីសបារាំង២រូប នៅកណ្តាលក្រុងប៉ារីស បានធ្វើឱ្យសន្លឹកឆ្នោតបេក្ខជន "ម៉ារីន ឡឺប៉ែន" បានឡើងខ្ពស់គួរឱ្យបារម្ភ។


អេម៉ានុយអែល ម៉ាក្រុង


បេក្ខនារី ម៉ារីន ឡឺប៉ែន

"ម៉ារីន ឡឺប៉ែន" បានប្រកាសដកខ្លួនពីដំណែងប្រធាននៃគណបក្សរបស់ខ្លួននៅ១សប្តាហ៍មុនពេលបោះឆ្នោត ក្នុងបំណងលាងខ្លួនឱ្យស្អាតពីទស្សនៈប្រកាន់ពូជសាសន៍នៃបក្សរបស់ខ្លួន តែនៅមានបំណងដកខ្លួនចេញពីសហភាពអឺរ៉ុពនៅឡើយ នេះក្នុងបំណងប្រមូលសន្លឹកឆ្នោត "ស្តាំកណ្តាលនិយម"បន្ថែម, ចៃដន្យមានព្រឹត្តិការណ៍ភរវកម្មមុនពេលបោះឆ្នោតសេចក្តីថ្លែងការណ៍ភ្លាមៗរបស់"ម៉ារីនេ ឡឺប៉ែន" បានឱ្យគេយល់ថាធ្វើឱ្យកើនសន្លឹកឆ្នោតបានច្រើនជាប្រាកដ។ រីឯសម្លេងឆ្នោតរបស់"អេម៉ានុអែលម៉ាក្រុង" ដែលបានលើស"ម៉ារីន ឡឺផែន"ទៅទៀតនោះគឺជាឆ្នោត"ដាស់អារម្មណ៍"ប្រទេសបារាំងថា លែងជឿលើនយោបាយ"ស្តាំកណ្តាលនិយមនៃជំនាន់មនុស្សចាស់"តទៅទៀតហើយ គឺត្រូវការនូវថាមពលសម្រាប់ផ្លាស់ប្តូរទៅរកនយោបាយថ្មីមួយផ្សេងទៀត។

គណបក្សលោក អេម៉ានុយអែល ម៉ាក្រុង មិនមានសមាជិករបស់ខ្លួននៅសភានៅឡើយទេ រីឯលោកស្រី ម៉ារីន ឡែប៉ែន មានសមាជិកតែ២រូបនៅសភាជាតិក្នុងចំណោមតំណាងរាស្ត្រប្រមាណជាង៥០០នាក់ អ្នកវិភាគនិយាយថា ប្រធានាធិបតីនាអណត្តិខាងមុខនឹងមិនមានអំណាចធំដូចប្រធានាធិបតីឯទៀតៗដែលមានសមាជិកច្រើននៅសភាជាតិនោះទេ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅសភាជាតិនឹងធ្វើនៅបន្ទាប់ពីការជ្រើសតាំងប្រធានាធិបតីបារាំងរួចមក។

ការបោះឆ្នោតជុំទី២នឹងធ្វើទៅថ្ងៃទី៧ខែឧសភាឆ្នាំ២០១៧នេះ៕

តមកទំព័រទី ០៣ ## ប្រធានាធិបតី"ឌុណល ត្រម"កាន់កាប់...

ក៏ធ្វើមិនបានដោយគ្មានភស្តុតាង, បាតុករដែលសម្តែងការមិនពេញចិត្តចំពោះការមិនគោរពគោលការសិទ្ធិមនុស្សសិទ្ធិស្ត្រីភេទនៅតែមានច្រើនធ្វើឱ្យស្ត្រីល្បីឈ្មោះ២រូបប្រកាសឈរឈ្មោះជាបេក្ខជនប្រធានាធិបតីនៅអាណត្តិក្រោយប្រជែងនឹង"ត្រម"គឺ អតីតស្ត្រីទី១ មីសែល អូបាម៉ា នឹងព្រឹទ្ធសមាជិករដ្ឋម៉ាសាឈូសិត អេលីសាបេតវ៉ារ៉ុន។

ក្នុងការទប់ស្កាត់ភេរវកម្ម"អាយស៊ីស"មជ្ឈឹមបូពា ប្រធានាធិបតីបានចេញបទបញ្ជាឱ្យលុបទិដ្ឋាការមិនឱ្យចូលស្រុកអាមេរិកពិប្រទេស៦ដែលអាចនាំគ្រោះថ្នាក់ដោយចំពោះមកសហរដ្ឋអាមេរិកដែលបណ្តាលឱ្យមានប្រតិកម្មពីសភាអឺរ៉ុបដែលជាសម្ពន្ធមិត្រអាមេរិក គេបានលុបទិដ្ឋាការស្វ័យប្រវត្តន៍ពីពលរដ្ឋអាមេរិកាំងវិញដែរ។ មានបទបញ្ជាប្រធានាធិបតីឱ្យវាយប្រហារលើទ័ពប្រធានាធិបតី"អាសាដនៃប្រទេសស៊ីរី"នៅពេលដែលស៊ីរីបានប្រើអាវុធគីមីប្រល័យពលរដ្ឋស៊ីវិលជាប្រជាជាតិខ្លួនឯង -ព្រឹត្តការណ៍នេះមានការគាំទ្រច្រើន។

ចំពោះកិច្ចការបរទេសវិញ លោកប្រធានាធីបតី "ត្រម"មិនបានចេញដំណើរទៅចងមេត្រីភាពទៅប្រទេសក្រៅច្រើន ដូចប្រធានាធិបតីមុនៗទេ តែព័តិមាននិយាយថា លោកមិនដែលចោលឱកាសទៅលេងកូនគោលនាចុងសប្តាហ៍នៅគេហដ្ឋានរបស់លោក នៅរដ្ឋហ្វ្លរីដាទេ។ លោករដ្ឋលេខាធិការថ្មីខាងកិច្ចការបរទេស ទីឡឺរ៉ុង ជាអ្នកពង្រឹងទំនាក់ទំនងចិន រុស្សី ទប់ស្កាត់សង្គ្រាមដែលចេះតែរកកល់នឹងផ្ទុះពីមជ្ឈឹមបូពា។

នៅពេលមានការបង្ករសង្គ្រាមពិប្រទេសកូរ៉េខាងជើងដោយប្រទេសនេះសាលល្បងអាវុធ "បរម៉ាណូ"ច្រើនដង, លោក "ត្រម"បានទុកឱកាសឱ្យប្រធានាធិបតីចិនជាអ្នកដោះស្រាយ, ចិនបានកាត់ធ្យូងថ្ម ហើយចុងក្រោយនេះចិនកាត់ការបញ្ជូនប្រេងសាំងធ្វើឱ្យកូរ៉េខាងជើងមានបញ្ហាក្នុងប្រទេសរបស់ខ្លួនច្រើន តែនៅតែចង់ជំនះប្រើអាវុធបរមាណូដដែល, ខែមេសានេះកូរ៉េខាងជើងបានគម្រាមថានឹងបាញ់កាំជ្រួចបរមាណូមកលើសហរដ្ឋអាមេរិក ដែលធ្វើឱ្យអាមេរិកបញ្ជូនអាវុធធំតូច នាវាដឹកយន្តហោះទៅត្រៀមធ្វើសង្គ្រាមវាយប្រហារកូរ៉េខាងជើងពីកូរ៉េខាងត្បូងប្រសិនបើមានការបាញ់កាំជ្រួចចេញមក



មែន, តែនៅពេលចុងសប្តាហ៍មុននេះជាថ្ងៃកំណត់កាំជ្រួចបានបាញ់ចេញមកមែនសង្គ្រាមរៀបនឹងផ្ទុះទៅហើយនោះ តែអកុសលកាំជ្រួចបរមាណូទាំងឡាយបានត្រូវខូចខាត ហោះចេញមិនរួច -ពេលជាមួយគ្នានោះ អាមេរិកបានបាញ់តបតដោយមីស៊ីលឆ្លងទ្វីប ពីឆ្នេរខាងលិច (កាលីហ្វរញ៉ា) ជាការគម្រៀមតបតវិញ យន្តហោះបានផ្តើមប្រតិបត្តិការលើកូរ៉េខាងជើង, លោកអនុប្រធានាធិបតី ម៉ាយ ផេន នៅប្រចាំបញ្ជាការនៅកូរ៉េខាងត្បូង។ នៅពេលដែលកូរ៉េខាងជើងតម្លើងឫទ្ធិនោះ អាមេរិកបានតម្លើងកម្លាំងសព្វាវុធយោធានៅជុំវិញកូរ៉េខាងត្បូងនឹងក្បែរតាយវ៉ាន់បានច្រើន ដែលចិនមិនមានការពេញចិត្តទាល់តែសោះពីព្រោះវាជាការគម្រាមដល់ការវាតទីត្រួតត្រាលើសមុទ្រចិនរបស់ចិនដែរ តែគ្មានជម្រើសនឹងការលុកលុយតំបន់របស់អាមេរិកនោះទេ។

ប្រជាប្រិយភាពនៃប្រធានាធិបតី"ឌុណល ត្រម"នៅតែឋិតនៅកំរិតទាបបំផុត គឺនៅកំរិតតិចជាង៤០% ដែលប្រធានាធិបតីមុនៗមានកំរិតខ្ពស់ជាង៥០-៦០% ជាដំរាបក្នុងរយពេលដដែលនេះ -នេះក៏ដោយសារ "ត្រម" មិនអាចប្រើយន្តការប្រជាធិបតេយ្យ តាមអំណាចដ៏ធំធេងដែលខ្លួនមាននោះទេ ជាពិសេសយន្តការប្រជាធិបតេយ្យនោះ បានបែងចែកអំណាចដាច់ពីដៃប្រធានាធិបតី, ហើយបើពលរដ្ឋបានជ្រើសរើសមនុស្សម្នាក់ខុសក៏នៅមានមនុស្សដែលគេបានជ្រើសរើសឱ្យកាន់ការងារជាតិឯទៀតៗធ្វើការត្រឹមត្រូវសម្រាប់តម្រែតម្រង់ឱ្យធ្វើការស្របច្បាប់ដែរ។ មានការបញ្ចេញមតិជាច្រើនថា លោកប្រធានាធីបតី "ឌុណល ត្រម"មិនអាចមានប្រជាប្រិយភាពឆ្លងទៅអាណត្តិទី២នោះរួចទេ៕

# ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យចុះផ្សាយពី ឌឹ ខេមបូឌា ដេលី


## កីឡាការិនីប៉េតង់មេដាយមាសពិភពលោក ត្រូវបានស្វាគមន៍នៅភ្នំពេញ

**ដោយ ឆន ភារុណ । ថ្ងៃពុធ ទី១៩ ខែមេសា ឆ្នាំ២០១៧**

បន្ទាប់ពីដណ្តើមបានមេដាយមាសក្នុងព្រឹត្តិការណ៍ប្រកួតជើងឯកកីឡាប៉េតង់ពិភពលោកនៅក្នុងប្រទេសប៊ែលហ្ស៊ិកកាលពីថ្ងៃអាទិត្យ លោកស្រី អ៊ុក ស្រីមុំ ត្រូវបានក្បួនម៉ូតូធំទៅទទួលកាលពីម្សិលមិញនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីអមដង្ហែលោកស្រីតាមផ្លូវមួយចំនួនឆ្ពោះមកពហុកីឡាដ្ឋានអូឡាំពិកសម្រាប់ពិធីមួយដែលរៀបចំឡើងដើម្បីអបអរសាទរជោគជ័យរបស់លោកស្រី ។

លោកស្រី អ៊ុក ស្រីមុំ ដណ្តើមបានមេដាយមាសក្នុងវិញ្ញាសាវាយឯកត្តជននារី? ដោយផ្តួលកីឡាការិនីបេជីម៉ូណា (BejiMouna) របស់ទុយនេហ្ស៊ីយ៉ាងស្រួលក្នុងពិន្ទុ១៣-៧ នៅវគ្គផ្តាច់ព្រ័ត្របន្ទាប់ពីផ្តួលកីឡាការិនី អ៊ុយដឺរ៉េ បង់ដេរ្យ៉ា (Audrey Bandiera) របស់បារាំងនៅវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងការប្រកួតនៅទីក្រុងហ្គែន (Ghent) ។

កម្ពុជាក៏ទទួលបានមេដាយដែរក្នុងវិញ្ញាសាវាយគូចម្រុះ ដោយកីឡាករ ញ៉ែម បូរ៉ា និងកីឡាការិនី ស្រ៊ាង សុរ៉ាឃីម ទទួលបានមេដាយប្រាក់ បន្ទាប់ពីចាញ់ទុយនេហ្ស៊ីនៅវគ្គផ្តាច់ព្រ័ត្រ ។

ដើម្បីអបអរសាទរជ័យលាភីអន្តរជាតិចុងក្រោយនៅក្នុងកីឡាដែលគេស្គាល់ថា ប៊ូលដែរនេះលោកស្រី អ៊ុក ស្រីមុំ ត្រូវបានក្បួនម៉ូតូធំចំនួន១២គ្រឿងទៅទទួលនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ហើយអមដង្ហែឆ្ពោះមកពហុកីឡាដ្ឋានជាតិអូឡាំពិក ។

លោកស្រី អ៊ុក ស្រីមុំ បានថ្លែងទៅកាន់ក្រុមអ្នកយកព័ត៌មានថា "ខ្ញុំសប្បាយចិត្តណាស់ រកអ្វីប្រៀបផ្ទឹមពុំបានទេ មានឧបសគ្គជាច្រើន" ។

លោកស្រី កែ ឡេង ជាកីឡាការិនីប៉េតង់ដ៏ល្បីល្បាញបំផុតរបស់កម្ពុជាដែលដណ្តើមបានមេដាយមាសរហូតដល់ទៅ១៧នៅទូទាំងពិភពលោកអំឡុងអាជីពរបស់ខ្លួន បានមានប្រសាសន៍ថា លោកស្រីសង្ឃឹមថា ការកើនឡើងជ័យជម្នះនៅក្នុងកីឡានេះនឹងជំរុញឱ្យក្មេងៗដើរតាមគន្លងរបស់គាត់ ។

លោកស្រីបានគូសបញ្ជាក់ថា "ជ័យជម្នះរបស់ ស្រីមុំ ជំរុញលើកទឹកចិត្តក្មេងជំនាន់ក្រោយ ។ ខ្ញុំពិតជាសប្បាយចិត្តជួសគាត់" ។

ប៉េតង់គឺជាកីឡាមួយក្នុងចំណោមកីឡាមួយចំនួនតូចដែលកម្ពុជាតែងតែទទួលបានជោគជ័យនៅលើឆាកអន្តរជាតិ ។ កីឡាដែលកីឡាករចូលលេងត្រូវបោះប៊ូលដែកឱ្យឈប់ជិតគ្រាប់ប៊ីនេះពេញនិយមយ៉ាងខ្លាំងអំឡុងសម័យអាណានិគមនិយមបារាំង សម្រាប់មន្ត្រីអាណានិគម និងកម្មករខ្មែរបង្កើតទំនាក់ទំនងជាមួយគ្នា ។

លោក ព្រុំ ឌិន អនុប្រធានទី១នៃសមាគមប៉េតង់ជាតិបានមានប្រសាសន៍ថា រហូតមកទល់ពេលនេះកម្ពុជាឈ្នះបានមេដាយប្រហែល១៥០នៅក្នុងការប្រកួតទូទាំងពិភពលោក ។

លោកថ្លែងថា ជាការលើកទឹកចិត្តសម្រាប់ការទទួលបានមេដាយមាសលោកស្រី អ៊ុក ស្រីមុំ នឹងទទួលបានប្រាក់រង្វាន់៤០.០០០ដុល្លារពីលោកនាយករដ្ឋមន្ត្រីហ៊ុនសែនដែលលោកស្រីនឹងត្រូវចូលជួបសម្តែងការគួរសមនៅថ្ងៃព្រហស្បតិ៍ ។

លោក ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំមានប្រសាសន៍ថា កីឡាករកីឡាការិនីទាំងពីរដែលប្រកួតក្នុងវិញ្ញាសាវាយគូចម្រុះក៏នឹងទទួលបានរង្វាន់ចំនួន៨០លានរៀល (ប្រហែល២០.០០០ដុល្លារ) ផងដែរ ៕ **សុខុម**



លោកស្រី អ៊ុក ស្រីមុំ ជិះលើរថយន្តអមដោយក្បួនម៉ូតូធំដង្ហែក្នុងរាជធានីភ្នំពេញបន្ទាប់ពីលោកស្រីដណ្តើមបានមេដាយមាសក្នុងព្រឹត្តិការណ៍ប្រកួតជើងឯកប៉េតង់ពិភពលោកនៅក្នុងប្រទេសប៊ែលហ្ស៊ិកកាលពីថ្ងៃអាទិត្យ ។ រូបថត: Emil Kastrup/ Cambodia Daily



លោកស្រី អ៊ុក ស្រីមុំ ជិះលើរថយន្តអមដោយក្បួនម៉ូតូធំដង្ហែក្នុង រាជធានីភ្នំពេញ បន្ទាប់ពីលោកស្រី ដណ្តើមបានមេដាយមាសក្នុងព្រឹត្តិការណ៍ប្រកួតជើងឯកប៉េតង់ពិភពលោកនៅក្នុងប្រទេសប៊ែលហ្ស៊ិកកាលពីថ្ងៃអាទិត្យ ។ រូបថត: Emil Kastrup/ Cambodia Daily

## CAMBODIA'S PETANQUE GOLDEN HEROINE CELEBRATED IN CAPITAL

by Chhorn Phearun | April 19, 2017

After picking up a gold medal at the World Petanque Championships in Belgium on Sunday, Ouk Sreymom was met by a motorcade on Tuesday at Phnom Penh International Airport and escorted through the streets to Olympic Stadium for a ceremony to mark her achievement.

Ms. Sreymom won gold in the women's singles, comfortably beating Tunisian BejiMouna 13-7 in the final after knocking out Audrey Bandiera of France in the semifinals of the tournament in Ghent.

Ouk Sreymom holds up her gold medal while riding through Phnom Penh atop a truck on Tuesday after winning the World Petanque Championships in Belgium on Sunday. (Emil Kastrup/The Cambodia Daily)

Cambodia also picked up medals in mixed doubles, with Nhem Bora and KhimSreang Sora taking silver after losing to Tunisia in the final.

To celebrate the latest international triumph in the sport-also known as boules-Ms. Sreymom was greeted by an escort of a dozen motorcycles at the capital's airport and shadowed to the stadium.

"I am very happy. Nothing is comparable…. There were a lot of obstacles," Ms. Sreymom told reporters.

Ke Leng, Cambodia's most famous petanque player, who has amassed 17 gold medals from across the globe during her career, said she hoped increased success in the sport would inspire youngsters to follow in her footsteps.

"Sreymom's victory encourages the future generation. I am very happy for her," Ms. Leng said.

Petanque is one of the few sports in which Cambodia regularly makes a mark on the world stage. The sport-a form of lawn bowling in which players throw metal balls to land near a small wooden ball called a jack-became popular during the French colonial era as a way for colonial officials and Cambodian workers to bond.

Prum Din, first vice president of the National Petanque Association, said Cambodia had now won about 150 medals at tournaments around the world.

As a reward for her success, Ms. Sreymom will be handed $40,000 from Prime Minister Hun Sen, whom she will meet on Thursday, Mr. Din said.

Education Minister Hang Chuon Naron said the mixed pair would also be given 80 million riel, or about $20,000.

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# រដ្ឋាភិបាលហាមមន្ត្រីគណបក្សសង្គ្រោះជាតិលែង ឱ្យចុះទៅសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារ

**ដោយវណ្ណ រឿននិងពនេ ភាវៀរ ។ ថ្ងៃសុក្រ ទី២១ខែមេសា ឆ្នាំ២០១៧**

ក្រសួងមហាផ្ទៃនឹងលែងអនុញ្ញាតឱ្យមន្ត្រីគណបក្សសង្គ្រោះជាតិចុះសួរសុខទុក្ខសហការីរបស់ខ្លួនដែលកំពុងជាប់ពន្ធនាគារទៀតហើយ បន្ទាប់ពីគណបក្សនេះបាននាំបុគ្គលិកម្នាក់របស់វិទ្យុអាស៊ីសេរី (RFA) ចូលក្នុងពន្ធនាគារក្រោមលេសមិនពិត ជាការអះអាងដែលគណបក្សនេះ និងបុគ្គលិកវិទ្យុខាងលើបានច្រានចោលថាមិនមែនជាការពិត។

លោក ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃបានមានប្រសាសន៍ថា លោក ហួត វុទ្ធី នាយករងវិទ្យុអាស៊ីសេរីប្រចាំប្រទេសកម្ពុជា ដែលប្រិយមិត្តអ្នកស្តាប់ស្គាល់ច្បាស់ថា ជុន ច័ន្ទបុត្រ បានចុះហត្ថលេខា និងសរសេរបញ្ជាក់តួនាទីរបស់ខ្លួនថាជា "ជំនួយការ" នៅពេលលោកអមដំណើរតំណាងរាស្ត្រគណបក្សសង្គ្រោះជាតិពីររូប គឺលោកស្រី មូរ សុខហួរ និងលោក ឡុង រី ចុះសួរសុខទុក្ខសកម្មជន និងអតីតមន្ត្រីគណបក្សដែលកំពុងជាប់ឃុំនៅពន្ធនាគារព្រៃស កាលពីថ្ងៃពុធ។

ឧត្តមសេនីយ៍រូបនេះបានថ្លែងកាលពីថ្ងៃពុធថា "ពួកគាត់មិនស្មោះត្រង់ជាមួយយើងទេ។ ពួកគាត់អនុញ្ញាតឱ្យ ជុន ច័ន្ទបុត្រ លួចចូលទៅជាមួយពួកគាត់...។ យើងនឹងផ្អាកលែងឱ្យពួកគាត់ចុះសួរសុខទុក្ខរយៈពេលវែង ដោយសារពួកគាត់ផ្សព្វផ្សាយសារនយោបាយ"។

អ្នកនាំពាក្យដដែលបន្តថា លោក ហួត វុទ្ធី អះអាងថាខ្លួនជា "ជំនួយការគណបក្សសង្គ្រោះជាតិ។ តាមពិតគាត់ជាអ្នកយកព័ត៌មានឱ្យអាស៊ីសេរី"។ ទោះជាយ៉ាងណាកាលពីម្សិលមិញ លោកមិនប្រាកដថា ទង្វើនេះបំពានច្បាប់ណាមួយឡើយ ដោយលើកឡើងថាការសម្រេចបន្តនីតិវិធីលើករណីនេះ?" ស្រេចលើតុលាការ"។ លោកមានប្រសាសន៍បន្ថែមទៀតថា "ក្នុងក្រមព្រហ្មទណ្ឌចែងថា ការធ្វើរឿងបែបនេះគឺមិនត្រឹមត្រូវទេ"។

ដែលគាំទ្ររដ្ឋាភិបាលបានបង្ហាញពីលោក ហួត វុទ្ធី ពាក់មួកកាតឹប និងពាក់វ៉ែនតាការពារពន្លឺព្រះអាទិត្យ ហើយឈរពីក្រោយខ្នងលោកស្រី មូរ សុខហួរ។ ស្ថាប័នសារព័ត៌មានមួយនេះក៏បានបង្ហោះរូបសៀវភៅចុះវត្តមានភ្ញៀវដែលសួរសុខទុក្ខអ្នកទោសផងដែរ ហើយវាបង្ហាញពីឈ្មោះផ្លូវការរបស់លោក ហួត វុទ្ធី អមដោយមុខតំណែងជា "ជំនួយការ"។

ប៉ុន្តែលោក ហួត វុទ្ធី មានប្រសាសន៍ថា លោកគ្រាន់តែសរសេរឈ្មោះរបស់លោកប៉ុណ្ណោះ ហើយមិនបានដាក់តួនាទីទេ។ លោកបានលើកឡើងកាលពីម្សិលមិញថា "ខ្ញុំមិនពាក់ព័ន្ធនឹងគណបក្សទេ។ ខ្ញុំគ្រាន់តែទៅយកព័ត៌មានប៉ុណ្ណោះ"។

លោក ហួត វុទ្ធី ដែលមានតួនាទីជាអ្នកសម្របសម្រួលកិច្ចសម្ភាស៍ និងកិច្ចប្រជុំតុមូលនៅស្ថានីយវិទ្យុខាងលើនេះដែរនោះប្រាប់ថា ដំបូង



រូបថតមួយសន្លឹកបង្ហោះលើគេហទំព័រព័ត៌មាន Fresh News

ឡើយលោកមានបំណងចូលសួរសុខទុក្ខលោក គឹម សុខ អ្នកអត្ថាធិប្បាយនយោបាយដែលត្រូវបានឃុំខ្លួនកាលពីខែកុម្ភៈដោយសារចោទប្រកាន់ថា "បណ្តាញ" មួយដែលមានទំនាក់ទំនងស្និទ្ធនឹងរដ្ឋាភិបាលជាអ្នករៀបចំការធ្វើឃាតលោក កែម ឡី អ្នកវិភាគនយោបាយ។ លោក គឹម សុខ បានធ្វើអត្ថាធិប្បាយបែបនេះអំឡុងពេលបទសម្ភាសន៍ដល់វិទ្យុអាស៊ីសេរី។

លោក ហួត វុទ្ធី បញ្ជាក់ថា ឆ្មាំពន្ធនាគារម្នាក់មិនអនុញ្ញាតឱ្យលោកចូលសួរសុខទុក្ខលោក គឹម សុខ ទេ ដោយនិយាយថា លោកត្រូវមានលិខិតអនុញ្ញាតពីតុលាការទើបអាចចូលបាន។

ប៉ុន្តែប៉ុន្មាននាទីក្រោយមកគណៈប្រតិភូនៃគណបក្សសង្គ្រោះជាតិក៏បានទៅដល់។ លោក ហួត វុទ្ធី មានប្រសាសន៍ថា លោកបានចូលទៅជាមួយគណៈប្រតិភូនេះ ហើយស្តាប់យ៉ាងស្ងៀមស្ងាត់នូវការសន្ទនារបស់ពួកគាត់ជាមួយអតីតមន្ត្រី?និងសកម្មជនគណបក្សប្រឆាំង១៦រូបដែលសុទ្ធតែត្រូវបានចោទប្រកាន់ក្នុងសំណុំរឿងចំនួនដែលគណបក្សសង្គ្រោះជាតិអះអាងថាជារឿងនយោបាយ។

លោកលើកឡើងថា "ខ្ញុំមិនខ្វល់ទេថា គេ

**តទៅទំព័រទី១៩**

# GOVERNMENT BARS CNRP FROM PRISON VISITS

**by Van Roeun and Ben Paviour | April 21, 2017**

The Interior Ministry will no longer allow CNRP officials to visit their jailed comrades after it accused the party of bringing a Radio Free Asia (RFA) staff member to a prison visit under false pretenses, a claim disputed by the party and the employee.

Huot Vuthy, an RFA local deputy director better known to listeners as Chun Chanboth, signed himself in as an "assistant" when he accompanied CNRP lawmakers Mu Sochua and Long Ry to the meeting with jailed party activists and former officials at Prey Sar prison on Wednesday, ministry spokesman KhieuSopheak said.

"They are not honest with us," General Sopheak said on Wednesday. "They let Chun Chanboth secretly go with them.… We will postpone their visits for a long time because they spread the political message."

Gen. Sopheak said Mr. Vuthy claimed to be "an assistant to the CNRP. In fact, he is a reporter for RFA." However, he was vague on Thursday about what laws might have been violated, saying any decision to pursue the case was "up to the courts."

"It states in the criminal code that to do this kind of thing is wrong," he said.

A photograph posted to the government-aligned Fresh News website showed Mr. Vuthy wearing a baseball cap and sunglasses and standing behind Ms. Sochua. The outlet also posted a photo of the purported sign-in book for the prison showing Mr. Vuthy's legal name alongside the title "assistant."

But Mr. Vuthy said he had simply signed his name and had not provided a title.

"I am not involved with the party," he said on Thursday. "I went to get the news."

Mr. Vuthy, who also hosts interviews and roundtables at the station, said he initially intended to visit political commentator Kim Sok, who was imprisoned in February for accusing a government-affiliated "network" of orchestrating the murder of political analyst Kem Ley. Mr. Sok made the comments in RFA interviews.

A guard turned Mr. Vuthy away from visiting Mr. Sok, saying he needed a permission letter from the courts, Mr. Vuthy said.

But the CNRP delegation arrived minutes later, and Mr. Vuthy said he joined them, listening silently to their conversation with 16 former opposition officials and activists, all of whom were charged in cases the CNRP has claimed are politically motivated.

"I don't care what I am accused of doing because I work based on journalism," he said. "I want to know the situation [inside the prison]. Everyone knows me. How can I disguise myself?"

Ms. Sochua said she stood by Mr. Vuthy's account of the visit, but said the CNRP would work with the ministry to resolve the situation.

"We have no intention whatsoever to disrespect the rules," she said. "We hope that the situation will be clarified…. And after clarification there will be a solution."

RFA and its guests have had a difficult year. Kem Ley, a social scientist and regular guest on the popular "Listener Forum" talk show, was gunned down in July, just days after speaking critically of alleged government corruption. Prime Minister Hun Sen warned another guest, Meas Nee, not to "go too far" in a speech in November, and sued Mr. Sok in February.

Council of Ministers spokesman PhaySiphanhas repeatedly claimed RFA and Voice of America are in cahoots with the U.S. government and the opposition party, with the clandestine aim of instilling chaos and instability through biased reporting. The U.S. government funds both stations.

Lao Mong Hay, a political analyst and regular guest on broadcasts hosted by Mr. Vuthy, said that it was the longtime editor's outspoken charisma that had landed him in the government's crosshairs.

"Actually, he is one of the harsh government critics," Mr. Mong Hay said.

"I fear that, in terms of popularity, he is next to Dr. Kem Ley."

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# គ.ជ.ប. នឹងរៀបចំកិច្ចពិភាក្សាប្រចាំថ្ងៃរបស់គណបក្សនយោបាយតាមកញ្ចក់ទូរទស្សន៍ និងវិទ្យុ

**ដោយវណ្ណ រឿន ។ ថ្ងៃពុធ ទី១៩ ខែមេសា ឆ្នាំ២០១៧**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) នឹងផ្សព្វផ្សាយកិច្ចពិភាក្សាប្រចាំថ្ងៃរៀបរាប់ពីគោលការណ៍របស់គណបក្សនយោបាយទាំងអស់ដែលកំពុងឈរឈ្មោះនៅក្នុងការបោះឆ្នោតឃុំ សង្កាត់នាពេលខាងមុខតាមវិទ្យុ និងទូរទស្សន៍ជាតិអំឡុងរយៈពេលយុទ្ធនាការឃោសនាបោះឆ្នោតដែលមានរយៈពេល១៤ថ្ងៃ នេះបើតាមលោក ហង្ស ពុទ្ធា អ្នកនាំពាក្យបានមានប្រសាសន៍កាលពីម្សិលមិញ។

លោក ហង្ស ពុទ្ធា បានថ្លែងថា គណបក្សនយោបាយនីមួយៗក្នុងចំណោមគណបក្សទាំង១២ដែលចូលរួមប្រកួតប្រជែងដណ្តើមអាសនៈនៅក្នុងការបោះឆ្នោតឃុំ សង្កាត់ថ្ងៃទី៤ ខែមិថុនានោះនឹងមានពេល៧នាទី និង៣០វិនាទីសម្រាប់ការផ្សព្វផ្សាយតាមរលកធាតុអាកាស ឬវិទ្យុដោយឥតគិតថ្លៃក្នុងមួយថ្ងៃចាប់ពីថ្ងៃទី២០ ខែឧសភាទៅនៅពេលរយៈពេលយុទ្ធនាការចាប់ផ្តើមស្តីពីកិច្ចពិភាក្សាដែលនឹងគ្របដណ្តប់លើប្រធានបទខុសៗគ្នា។

លោកបានមានប្រសាសន៍ថា សម្រាប់ការផ្សព្វផ្សាយអំឡុងយុទ្ធនាការ រាល់ខ្លឹមសារទាំងអស់នឹងត្រូវអនុម័តយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប.) ដើម្បីធានាការអនុវត្តតាមច្បាប់យុទ្ធនាការឧទាហរណ៍ដើម្បីបញ្ចៀសការវាយប្រហារលើបុគ្គលជាដើម។

លោកបានថ្លែងថា "ប្រសិនបើពួកគេមិនឆ្លងកាត់គ.ជ.ប.ទេនោះ យើងមិនទទួលខុសត្រូវក្នុងការជួយការពារពួកគេឡើយ"។

នៅក្នុងសេចក្តីប្រកាសកាលពីសប្តាហ៍មុន គ.ជ.ប.បានលើកឡើងថា ម្ចាស់ស្ថានីយវិទ្យុ និងទូរទស្សន៍ទាំងអស់មិនត្រូវបានអនុញ្ញាតឱ្យលក់ស្ប៉តពាណិជ្ជកម្មផ្តាច់មុខទៅឱ្យគណបក្សនយោបាយណាមួយឡើយ ហើយការហែក្បួនតាមដងផ្លូវត្រូវបានអនុញ្ញាតតែនៅថ្ងៃបើក និងថ្ងៃបិទនៃរយៈពេលយុទ្ធនាការតែប៉ុណ្ណោះ។

លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានមានប្រសាសន៍ថា គណបក្សកាន់អំណាចនឹងមិនរំខានជាមួយនឹងការទិញម៉ោងផ្សាយនៅតាមស្ថានីយឯកជនឡើយ ពីព្រោះអ្នកបោះឆ្នោតបានដឹងពីសមិទ្ធផលរបស់គណបក្សរួចហើយ។

លោកបានថ្លែងថា "យើងមិនចាំបាច់ទិញម៉ោងផ្សាយទេ ពីព្រោះយើងបានបង្ហាញនូវការអភិវឌ្ឍរបស់យើងរួចហើយ ហើយប្រជាពលរដ្ឋដឹងពីរឿងនេះយ៉ាងច្បាស់"។

មន្ត្រីគណបក្សសង្គ្រោះជាតិមិនអាចទាក់ទងភ្លាមៗដើម្បីសុំការអត្ថាធិប្បាយបានឡើយកាលពីម្សិលមិញ។

លោក យ៉េង វីរៈ ប្រធានគណបក្សប្រជាធិបតេយ្យមូលដ្ឋានបានមានប្រសាសន៍ថា លោកមិនទាន់ប្រាកដថា តើគណបក្សរបស់លោកនឹងចំណាយប្រាក់ទិញម៉ោងផ្សាយឬយ៉ាងណានោះនៅឡើយទេ។

លោកបានថ្លែងថា "អ្វីដែលខ្ញុំដឹងច្បាស់គឺថា យើងនឹងចូលរួមក្នុងកម្មវិធីណាមួយរបស់គ.ជ.ប. និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ"។

សេចក្តីប្រកាសរបស់គ។ជ។ប។ក៏បានលើកឡើងផងដែរថា គណៈកម្មាធិការនេះនឹងចោទប្រកាន់ចំពោះគណបក្សណាផ្សព្វផ្សាយខ្លឹមសារដែលស្ថាប័នរដ្ឋនេះចាត់ទុកថា ខុសច្បាប់។

សេចក្តីប្រកាសដដែលនេះមានខ្លឹមសារថា "ក្នុងករណីគ.ជ.ប.រកឃើញថា ខ្លឹមសារនៃការឃោសនារំលោភលើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៧ គ.ជ.ប.មានសិទ្ធិស្នើឱ្យគណបក្សនយោបាយធ្វើការកែតម្រូវ ហើយប្រសិនបើនៅតែមិនព្រមកែតម្រូវគ.ជ.ប.មានសិទ្ធិដកហូត ឬបញ្ឈប់លែងឱ្យស្ថានីយវិទ្យុ និងទូរទស្សន៍នោះធ្វើការផ្សព្វផ្សាយនូវខ្លឹមសារឃោសនាទាំងស្រុង និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន"។

កាលពីដើមខែនេះ គណបក្សសង្គ្រោះជាតិបានបោះបង់ចោលពាក្យស្លោកយុទ្ធនាការដែលបានចេញផ្សាយកាលពីពេលថ្មីៗក្រោមចំណងជើងថា "ដូរមេឃុំបម្រើបក្សដាក់មេឃុំបម្រើរាស្ត្រ" ខណៈគណបក្សប្រជាជនកម្ពុជាអះអាងថា វាជាការប្រមាថ និងខុសច្បាប់៕

សារុន (រាយការណ៍បន្ថែមដោយ Hannah Hawkins)

# NEC TO HOST DAILY PARTY PANEL DISCUSSIONS ON TELEVISION, RADIO

**by Van Roeun | April 19, 2017**

The National Election Committee will broadcast daily interview panels featuring all political parties that are running in upcoming local elections on state-run television and radio stations during the 14-day election campaign period, spokesman Hang Puthea said on Tuesday.



Hang Puthea, who was named the presumptive 'neutral' candidate on the new National Election Committee, sits at a coffee shop in Phnom Penh in 2015. (Siv Channa/The Cambodia Daily)

Mr. Puthea said each of the 12 parties vying for seats in the June 4 commune elections would get 7 minutes and 30 seconds of free airtime per day starting on May 20, when the campaign period begins, on a panel discussion that will cover different topics.

As for campaign advertising, all material would need to be approved by the National Election Committee (NEC) to ensure compliance with campaign laws, for example by avoiding personal attacks, he said.

"If they do not go through the NEC, we are not responsible for helping defend them," he said.

In a statement last week, the NEC said radio and TV station owners are not allowed to sell advertising spots exclusively to any one political party, and street parades are only permitted on the opening and closing days of the campaign period.

CPP spokesman Sok Eysan said the ruling party would not bother buying advertising on private stations, as voters already knew the party's achievements.

"We do not need to buy airtime because we have already showcased our development, and the people know it very well," he said.

CNRP officials could not immediately be reached on Tuesday.

Yeng Virak, president of the Grassroots Democracy Party, said he was not sure yet if his party would spend money on advertising.

"What I do know clearly is that we will participate in any programs by the NEC and independent media," he said.

The NEC's statement also said the committee could press charges against parties that broadcast material deemed illegal by the state election body.

"In the case that the NEC finds that the essence of the campaign violates the rules and procedures for the 2017 commune elections, the NEC is entitled to ask that political party to make corrections, and if it refuses to make corrections, the NEC has the right to deprive…stations from broadcasting its whole campaign and will take legal action," it said.

Earlier this month, the opposition CNRP abandoned its newly released campaign slogan-"Change commune chiefs who serve the party and replace them with commune chiefs who serve the people"-after the ruling CPP claimed it was offensive and illegal.

(Additional reporting by Hannah Hawkins)

ឌី ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌី ខេមបូឌា ដេលី

# លោក កឹម សុខា ប្រាប់អ្នកគាំទ្រថា សង្គ្រោះជាតិ ចង់បានសន្តិភាពមិនមែនសង្គ្រាម

**ដោយគុជ ណារ៉េន។ ថ្ងៃពុធ ទី២៦ខែមេសា ឆ្នាំ២០១៧**

កាលពីម្សិលមិញលោក កឹម សុខា ប្រធានគណបក្សសង្គ្រោះជាតិបានលើកឡើងថា គណបក្សរបស់លោកចង់ឱ្យមានការផ្លាស់ប្តូរប្រកបដោយសន្តិវិធីតែប៉ុណ្ណោះ ដោយច្រានចោលការអះអាងម្តងហើយម្តងទៀតរបស់គណបក្សប្រជាជនកម្ពុជាដែលថា ជ័យជម្នះនៅក្នុងការបោះឆ្នោតរបស់គណបក្សប្រឆាំងនឹងនាំសង្គ្រាមដល់ប្រទេសកម្ពុជានោះ។

លោក កឹម សុខា បានលើកឡើងនៅទីស្នាក់ការកណ្តាលរបស់គណបក្សសង្គ្រោះជាតិក្នុងរាជធានីភ្នំពេញថា "យើងមិនធ្វើឱ្យមានការផ្លាស់ប្តូរតាមរយៈរដ្ឋប្រហារ សង្គ្រាម បដិវត្តន៍ ឬទម្រង់អំពើហិង្សាផ្សេងៗជាដាច់ខាត"។

លោក កឹម សុខា បានលើកឡើងទៀតថា សមាជិកគណបក្សប្រឆាំងគ្មានបទពិសោធន៍ធ្វើសង្គ្រាម និងគ្មានអាវុធសម្រាប់បាញ់ទេ ហើយគ្មានជម្លោះជាមួយពលរដ្ឋខ្មែរផ្សេងៗទៀត ឬប្រទេសជិតខាងនោះឡើយ។

លោកបានមានប្រសាសន៍ថា "យើងមិនមែនទៅប្រយុទ្ធគ្នា ទៅវាយតប់គ្នា ឬឈ្លោះជាមួយនរណាម្នាក់នោះឡើយ ប៉ុន្តែយើងកំពុងដើរឆ្ពោះទៅកាន់ការបោះឆ្នោត...សម្រាប់ការផ្លាស់ប្តូរដោយវិជ្ជមាន"។

ទោះជាយ៉ាងណា លោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាបានលើកឡើងថា កម្មវិធីនយោបាយរបស់គណបក្សប្រឆាំងមួយនេះកើតចេញពីបំណងសងសឹកនិងដើរតាមលំអានរបស់ខ្មែរក្រហម ដោយលើកឡើងនូវអ្វីដែលលោកអះអាងថា ជាការអះអាងម្តង ហើយម្តងទៀតរបស់លោក សម រង្ស៊ី អតីតប្រធានគណបក្សសង្គ្រោះជាតិថា គណបក្សប្រឆាំងនឹងយកដីពីអ្នកមានចែកឱ្យអ្នកក្រ។

លោកបានសរសេរសារនៅក្នុងកម្មវិធីតេឡេក្រាមថា "តាមរយៈសារនយោបាយនេះគេគ្រប់គ្នាអាចមើលដឹងថា ចៀសមិនផុតពីកើតសង្គ្រាមនោះឡើយ"។ លោកបានសរសេរបន្ថែមថា "ឥឡូវនេះប្រធានគណបក្សថ្មីបានលើកឡើងថានឹងគ្មានសង្គ្រាមទេប្រសិនបើពួក គេឈ្នះឆ្នោត។ វាគ្រាន់តែជាពាក្យបោកប្រាស់ប្រជាពលរដ្ឋប៉ុណ្ណោះ"។

លោក ហ៊ុន សែន ជាធម្មតាតែងតែក្រើនរំឭកអ្នកបោះឆ្នោតថា លោក និងគណបក្សប្រជាជនកម្ពុជាបាននាំសុខសន្តិភាពជូនកម្ពុជាបន្ទាប់ពីមានសង្គ្រាមរាប់ទសវត្សរ៍ ហើយថា គូប្រជែងរបស់លោក នឹងធ្វើឱ្យសង្គ្រាមនេះត្រឡប់មកវិញ ជាការលើកឡើងដែលអ្នកវិភាគនិយាយថា គ្មានប្រសិទ្ធភាពចំពោះអ្នកបោះឆ្នោតក្មេងៗដែលមិនមានអារម្មណ៍ជិតដាមដោយអំពើហិង្សានាពេលអតីត។

កាលពីថ្ងៃច័ន្ទ លោកនាយករដ្ឋមន្ត្រីបានចាប់ផ្តើមប្រើពាក្យពេចន៍ទូគោះបោះបោកអំឡុងរដូវបោះឆ្នោត ដោយលើកឡើងពាក់ព័ន្ធគូប្រជែងដែលលោកអះអាងថានឹងជំរុញឱ្យមានសង្គ្រាម។

លោក ហ៊ុន សែន បានមានប្រសាសន៍



លោក កឹម សុខា ថ្លែងទៅកាន់សមាជិកគណបក្សសង្គ្រោះជាតិអំឡុងសមាជឥតព្រៀងទុកនៅទីស្នាក់ការកណ្តាលរបស់គណបក្សនេះក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ។
រូបថត: ស៊ីវ ចាន់ណា,ឌី ខេមបូឌា ដេលី

អំឡុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានថ្មីមួយនៅក្នុងខេត្តកណ្តាលតភ្ជាប់ប្រទេសកម្ពុជា និងវៀតណាមថា "នៅពេលខាងមុខពិតណាស់មានអ្នកដែលចង់បានសន្តិភាព និងអ្នកថែរក្សាសន្តិភាព ដើម្បីធានាការអភិវឌ្ឍតែក៏មានអ្នកចង់បាននូវជម្លោះជាមួយប្រទេស ជិតខាងដែរ"។ លោកបានមានប្រសាសន៍បន្ថែមថា "ខ្ញុំគិតថាប្រជាពលរដ្ឋរស់នៅតាមព្រំដែនទាំងអស់ចង់បានសន្តិភាព និងការអភិវឌ្ឍមិនមែនសង្គ្រាមនោះទេ"។

**តទៅទំព័រទី ១៩**



សមាជិកគណបក្សសង្គ្រោះជាតិបោះឆ្នោតអំឡុងសមាជឥតព្រៀងទុកនៅទីស្នាក់ការកណ្តាលរបស់គណបក្សនេះក្នុងរាជធានីភ្នំពេញកាលពីម្សិលមិញ។ រូបថត: ស៊ីវ ចាន់ណា,ឌី ខេមបូឌា ដេលី

# WE WAGE PEACE, NOT WAR, KEM SOKHA SAYS

**by KuchNaren | April 26, 2017**

CNRP President KemSokha on Tuesday said his party had only peaceful intentions for change, rebutting repeated CPP claims that an opposition party election victory would bring war to Cambodia.

"We are absolutely not making a change through a coup, war, revolution or other forms of violence," Mr. Sokha said at CNRP headquarters in Phnom Penh.

Opposition party members have no experience in combat, no guns with which to shoot, and no conflict with other Cambodians or its neighbors, Mr. Sokha said.

"We do not go to fight, to beat or argue with anyone, but we are walking to the election…for positive change."

CPP spokesman SokEysan, however, said the opposition's platform was fueled by a desire for vengeance and drew from the Khmer Rouge's playbook, citing what he asserted were repeated claims by former party president Sam Rainsy that the opposition would redistribute land from the rich to the poor.

"Everybody can see from this political message that war will unavoidably occur," he wrote over the messaging app Telegram. "Now the new party president said there will be no war if they win the election. It's just some words to trick people."

Mr. Hun Sen regularly reminds voters that he and the CPP brought peace to Cambodia after decades of war, and that his rivals would undo this work-a selling point analysts say resonates less with younger voters who have no memory of past violence.

As recently as Monday, the prime minister took to his election season doomsaying around his allegedly war-mongering rivals.

"In the future, of course, there are some people who want peace and to keep peace to ensure development, but there are some who want to bring conflict in relationships with neighboring countries," Mr. Hun Sen said at the inauguration of a new bridge in Kandal province connecting Vietnam and Cambodia.

"I think that all people living along the border want to have peace and development, not war," he added.

The opposition has repeatedly drawn attention to alleged Vietnamese border incursions into Cambodia and the political connections between Hanoi and the CPP, sometimes with fiery, racist undertones that mark one of its more potent political aces.

But Mr. Sokha appeared to discourage party members from such language on Tuesday.

"We do not consider any country to be our enemy, especially neighboring countries, **Continued to Page 15**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី

# កម្ពុជាស្នើឱ្យមានការកែប្រែកិច្ចព្រមព្រៀង បញ្ជូនពលរដ្ឋពីអាមេរិក

**ដោយឃី សុវុឌ្ឍី ។ ថ្ងៃពុធ ទី១ខែមីនា ឆ្នាំ២០១៧**

មន្ត្រីម្នាក់បាននិយាយកាលពីម្សិលមិញថា ក្នុងការខិតខំប្រឹងប្រែងធ្វើយ៉ាងណាកុំឱ្យមានការបញ្ជូនពលរដ្ឋកម្ពុជាដែលរងការគំរាមកំហែងពីសហរដ្ឋអាមេរិកមកកម្ពុជាវិញទាំងក្រុមគ្រួសារនោះ? ក្រសួងការបរទេសមានគម្រោងផ្តល់ជូនសហរដ្ឋអាមេរិកនូវកំណែប្រែថ្មីនៃកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍រវាងប្រទេសទាំងពីរ ។

លោក អ៊ូច បូរិទ្ធ រដ្ឋលេខាធិការក្រសួងការបរទេសបានមានប្រសាសន៍ថា ក្រសួងកំពុងពិនិត្យមើលអនុស្សរណៈនៃការយោគយល់ (MoU) ឆ្នាំ២០០២ ដែលអនុញ្ញាតឱ្យមានការបញ្ជូនពលរដ្ឋកម្ពុជាដែលត្រូវបានផ្តន្ទាទោសពាក់ព័ន្ធបទឧក្រិដ្ឋនៅសហរដ្ឋអាមេរិកត្រឡប់មកវិញ ដោយផ្អែកលើច្បាប់អន្តរជាតិនិងច្បាប់ស្តីពីសិទ្ធិមនុស្ស ។

លោកបានថ្លែងថា ក្រសួងចង់ធ្វើវិសោធនកម្ម MoU នេះ ពីព្រោះអ្នកដែលត្រូវបានបញ្ជូនត្រឡប់មកវិញនោះ? គឺជាសាច់ឈាមខ្មែររបស់យើង" ហើយដោយសារពលរដ្ឋខ្មែរឆ្អែតឆ្អន់នឹងការបែកពីក្រុមគ្រួសាររបស់ខ្លួនយូរលង់ណាស់មកហើយ ។

លោកបានមានប្រសាសន៍បន្តថា "ពលរដ្ឋខ្មែរប្រហែលជាគ្រប់គ្រាន់ពីរឿងនេះហើយ ។ ដូច្នេះហើយមិនចង់បន្តឱ្យមានការបែកពីគ្រួសារទៀតទេ" ។

លោក អ៊ូច បូរិទ្ធ បានថ្លែងទៅកាន់អ្នកយកព័ត៌មានអំឡុងសន្និបាតបូកសរុបលទ្ធផលការងារថ្ងៃទី១នៃសន្និបាតដែលមានរយៈពេលពីរថ្ងៃនៅទីស្តីការក្រសួងក្នុងរាជធានីភ្នំពេញថា ក្រសួងទទួលបានសំណើពីពលរដ្ឋកម្ពុជាដែលរស់នៅសហរដ្ឋអាមេរិក ហើយក៏ទទួលបានពីសំណើពីសាច់ញាតិរបស់ពួកគេផងដែរ ។

លោកបានថ្លែងថា ក្រសួងកំពុងវាយតម្លៃចំណុចនីមួយៗនៃ MoU នេះ ហើយស្នើឱ្យសហរដ្ឋអាមេរិកសហការធ្វើយ៉ាងណាឱ្យមានការកែប្រែសមស្របណាមួយ ។ លោកបានបន្តថា "យើងនឹងបញ្ជូនសំណើនេះទៅឱ្យសហរដ្ឋអាមេរិកពិនិត្យក្នុងពេលឆាប់ៗនេះ" ។

ក្រសួងបានស្នើកាលពីខែតុលាឱ្យផ្អាកកិច្ចព្រមព្រៀងនេះជាបណ្តោះអាសន្នសិន រហូតដល់មានការកែប្រែ "ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវ



លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសថ្លែងអំឡុងសន្និបាតបូកសរុបលទ្ធផលការងារនៅទីស្តីការក្រសួងស្ថិតក្នុងរាជធានីភ្នំពេញ កាលពីម្សិលមិញ ។
រូបថត: Emil Kastrup/ The CambodiaDaily

និងឱ្យនិវត្តជនទាំងនេះសម្របខ្លួនក្នុងសង្គមកម្ពុជាវិញសិន ។ ស្ថានទូតអាមេរិកប្រចាំរាជធានីភ្នំពេញបានលើកឡើងនៅពេលនោះថា MoU នេះ នៅមានប្រសិទ្ធភាពដដែល ហើយគ្មានការកែប្រែឡើយ ។

នៅក្នុងអ៊ីម៉េលកាលពីម្សិលមិញ លោក David Josar អ្នកនាំពាក្យរងនៅស្ថានទូតអាមេរិកបានលើកឡើងថា រដ្ឋាភិបាលកម្ពុជាបានប្រាប់ស្ថានទូតពីបំណងរបស់ខ្លួនឱ្យមានការពិភាក្សាឡើងវិញពីចំណុចមួយចំនួននៃ MoU នេះ ដែលរួមមានចំណុចដែលអនុញ្ញាតឱ្យប្រទេសទាំងពីរកោះប្រជុំគណៈកម្មការទ្វេភាគីដើម្បីពិភាក្សាបញ្ហាគោលនយោបាយមាតុភូមិនិវត្តន៍នេះ ។ លោកបានថ្លែងថា គេរំពឹងថាគណៈកម្មការនឹងកោះប្រជុំក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ ។

ពលរដ្ឋកម្ពុជាជាង៥០០នាក់ត្រូវបានបញ្ជូនពីសហរដ្ឋអាមេរិកមកកម្ពុជាវិញចាប់តាំងពីឆ្នាំ២០០២មក នេះបើយោងតាមលើកឡើងរបស់មណ្ឌលទ្រទ្រង់ជនមាតុភូមិនិវត្តន៍សមាហរណកម្ម ជាអង្គការមិនមែនរដ្ឋាភិបាលដែលជួយពលរដ្ឋកម្ពុជា ពេលពួកគេត្រឡប់មកដល់ប្រទេសវិញ ។ និវត្តជនជាច្រើនបានកើតក្នុងជំរំជនភៀសខ្លួនក្នុងទឹកដីថៃ ហើយបានធ្វើអន្តោប្រវេសន៍ទៅកាន់សហរដ្ឋអាមេរិកក្នុងវ័យកុមារ ហើយមិនដែលបានរស់នៅក្នុងប្រទេសកម្ពុជាទេ ។

កាលពីដើមខែនេះ ក្រុមមន្ត្រីបានលើកឡើងថា កម្ពុជានឹងទទួលយកពលរដ្ឋរបស់ខ្លួនជាង៣០នាក់ ដែលគ្រោងបញ្ជូនពីសហរដ្ឋអាមេរិកមកវិញ ហើយទន្ទឹមនឹងនោះដែរក៏បានបញ្ជាក់ឡើងពីបំណងរបស់ខ្លួនឱ្យមានការកែប្រែកិច្ចព្រមព្រៀងមាតុភូមិនិវត្តន៍ដោយផ្អែកលើមូលដ្ឋានមនុស្សធម៌ ។

ក្រុមមួយដែលបាននិងកំពុងជួយនិវត្តជនទាំងនោះឈ្មោះថា I Love Cambodia បានអំពាវនាវឱ្យមានការតវ៉ាជំទាស់នឹងការបញ្ជូនត្រឡប់មកវិញនេះ ។ សារុន (រាយការណ៍បន្ថែមដោយ Matt Surrusco)

Continued from page 01

## MINISTRY WORKING ON REVISION...

on the basis of international and human rights law, said Ouch Borith, a secretary of state at the ministry.

Mr. Borith said the ministry wanted to amend the MoU because those who are deported "are our Cambodian blood" and because Cambodians have long been "fed up" with having their families separated.

"Cambodian people have had just about enough of this, so do not continue to allow more family separation," he said.

Mr. Borith told reporters during the first day of a two-day annual meeting headed by Foreign Minister PrakSokhonn at the ministry's headquarters in Phnom Penh that it had received suggestions from Cambodian people who lived in the U.S. and also from their relatives.

The ministry was evaluating each section of the MoU and would request that the U.S. cooperates and makes appropriate changes, Mr. Borith said.

"We will send it soon to the U.S. for review," he said.

The ministry requested in October that the agreement be temporarily suspended until it was amended "to implement properly and effectively the integration of the returnees into Cambodian society." The U.S. Embassy in Phnom Penh said at the time that the MoU remained "in force and unchanged."

In an email on Tuesday, U.S. Embassy deputy spokesman David Josar said the Cambodian government had informed the embassy of its desire to renegotiate aspects of the MoU, which includes a provision allowing either country to convene a bilateral commission to discuss repatriation policy issues.

A commission was expected to convene in the coming months, he said.

More than 500 Cambodians have been deported from the U.S. since 2002, according to the Returnee Integration Support Center, an NGO that assists Cambodians upon their arrival in the country. Many returnees were born in Thai refugee camps, migrated to the U.S. as children and had never lived in Cambodia.

Earlier this month, officials said Cambodia would accept more than 30 of its citizens who were slated for deportation from the U.S., while also reiterating the government's wish to revise the repatriation agreement on humanitarian grounds.

A group that has been lobbying for an amended MoU, 1Love Cambodia, called for protests against the deportations.

តមកទំព័រទី ០១

# ពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំរកានៅសហរដ្ឋ...

ជាឱកាសនៃការធ្វើបុណ្យកុសលរួមគ្នានៅវត្តអារាម, ការជួបជុំគ្នាគ្រួសារ, ការលេងល្បែងប្រជាប្រិយ, និងការរាំកំសាន្តជាដើម។ សម្រាប់ឆ្នាំនេះ ប្រជាជនខ្មែរនៅក្នុងប្រទេសបានប្រារព្ធពិធីចូលឆ្នាំថ្មីរយៈពេល៣ថ្ងៃ ចាប់នៅថ្ងៃទី១៤ ដល់១៦ ខែមេសា ដោយមានប្រជាជនជាច្រើនបានធ្វើដំណើរទៅកាន់ស្រុកកំណើត ដើម្បីជួបជុំក្រុមគ្រួសារ, បងប្អូន និងសាច់ញ្ញាតិ និងមួយចំនួនទៀតបានធ្វើដំណើរទៅកាន់រមណីយដ្ឋាននានា។ ចំណែកពលរដ្ឋខ្មែរនៅក្រៅប្រទេសវិញជាពិសេសក្រុងឡូវែលជាទីកន្លែងដែលមានសហគមន៍ខ្មែររស់នៅច្រើនជាងគេបន្ទាប់ពីរដ្ឋកាលីហ្វញ្ញាដូចសព្វមួយដង ក៏បានរៀបចំកម្មវិធីអបអរសាទរឆ្នាំថ្មីដែរ។

កម្មវិធីចូលឆ្នាំថ្មី ២០១៧ នេះត្រូវបានរៀបចំឡើងនៅថ្ងៃសៅរ៍ទី២២ ខែមេសានេះ នៅទីតាំងចំនួន ២ កន្លែង ដោយទីតាំងទី១ ប្រព្រឹត្តទៅនៅទីតាំង Lowell Senior Center ដោយចាប់ផ្តើមពីម៉ោង ៩ ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ មានការរៀបចំឡើងដោយសមាគមន៍ខ្មែរ CMAA។ ក្នុងព្រឹត្តការណ៍នោះ មានការនិមន្តព្រះសង្ឃដើម្បីសូត្រមន្ត, ការរាំរបាំជូនពរដោយក្រុមរបាំអង្គរ, ការទទួលទានអាហាររួមគ្នា និងការរាំកំសាន្តប្រពៃណីខ្មែរ និងមានមានការចូលរួមពីសំណាក់លោកអភិបាលក្រុង Edward J។ Kennedy, លោក CorieBerlinger,អ្នកស្រី Rita Mercier, លោក William Taylor, តំណាងស្ថាប័ណ្ណ និងក្រុមហ៊ុននិងប្រជាពលរដ្ឋប្រហែល


ស្រង់ព្រះនៅវត្តត្រៃរតនារាម



៤០០នាក់។

លោកនាយកសមាគមខ្មែរ សុវណ្ណា ពៅ បានឱ្យខ្មែរផុសដឹងថា ការរៀបចំកម្មវិធីចូលឆ្នាំថ្មីនេះ មិនមែនជាលើកទីមួយនោះទេ នេះគឺជាលោកទី៨ ហើយដែលសមាគមបានរៀបចំឡើង។ លោកបានបន្ថែមទៀតថា គោលបំណងនៃការរៀបចំនេះ គឺដើម្បីធ្វើការជួបជុំបងប្អូនពលរដ្ឋខ្មែរ ដើម្បីអបអរបុណ្យចូលឆ្នាំប្រពៃណីខ្មែរទាំងអស់គ្នា និងចង់ឱ្យខ្មែរដឹងថា នៅអាមេរិចមានពលរដ្ឋខ្មែរជាច្រើនរៀបចំកម្មវិធីបុណ្យនេះ និងចង់ថែរក្សាវប្បធម៌ប្រពៃណីខ្មែរកុំឱ្យបាត់បង់។ ចំណែកលោកសុផល ដែលបានចូលរួមកម្មវិធីនេះ ក៏បានមានប្រសាសន៍ឱ្យខ្មែរផុសដឹងថា លោកពិតជារីករាយដែលមានការរៀចចំកម្មវិធីបុណ្យចូលឆ្នាំថ្មីខ្មែរ និងបានជួបជុំមិត្តភ័ក្តិនិងអ្នកផ្សេងទៀតជាច្រើន ដោយហូបអាហារជុំគ្នា និងបាននិយាយគ្នាលេង។


ប្រគេនចង្ហាន់នៅវត្តពន្លឺពុទ្ធចក្រ

នៅចុងបញ្ចប់នូវកម្មវិធីមានក៏មានព្យុហយាត្រាឆ្ពោះទៅកាន់ឧទ្យានក្លេមិនតេ ដោយមានការច្រៀងរាំជាមួយនិងក្រុមភ្លេងឆៃយាំ។ លោកសុវណ្ណា បានលើកឡើងថា ការធ្វើព្យុហយាត្រានេះ គឺក្នុងគោលបំណងដើម្បីជួយគ្រាំដល់កម្មវិធីអបអរសាទរបុណ្យចូលឆ្នាំនៅឯឧទ្យានក្លេមិនតេ..។




លោកចៅក្រុងចូលរួមបុណ្យចូលឆ្នាំសហគមន៍ខ្មែរ

នៅឧទ្យានក្លេមិនតេក៏មានការរៀបចំកម្មវិធីអបអរសាទរបុណ្យចូលឆ្នាំថ្មី ដែលរៀបចំឡើងដោយគណៈកម្មការក្លេមិនតេផាក (Clemente Park Committee) ហើយដែលព្រឹត្តការណ៍នេះវាគឺជាការរៀចចំលើកទី៦ ដែលចាប់ផ្តើមពីម៉ោង ១២ រសៀវរហូតដល់ម៉ោង ៥ ល្ងាច និងមានអ្នកចូលរួមទាំងពលរដ្ឋខ្មែរ និងបរទេសយ៉ាងច្រើនកុះករ ដោយមានការរាំកំសាន្តជាមួយក្រុមតន្ត្រីសម័យខ្មែរ, ការលេងល្បែងទាញព្រាត់ និងការដាក់លក់ផលិតផល និងម្ហូបអាហារសម្រាប់អ្នកចូលរួមផងដែរ៕

LICO WIRELESS, INC
boostmobile metroPCS T-Mobile
ទូរស័ព្ទ & កុំព្យូទ័រ
ជួសជុល . ទូរទាត់វិក័យប័ត្រ
មិនគិតថ្លៃការពិគ្រោះពិនិត្យ

បើកថ្ងៃចន្ទ _ ថ្ងៃសៅរ៍ ១០ព្រឹក_៧យប់
978-735-4100
336 Westford Street, Unit1. Lowell, MA 01851

Continued from page 13

## WE WAGE PEACE, NOT WAR...

because we will have mutual respect with decency-respect for sovereignty, respect for territorial integrity," he said.

Mr. Sokha also instructed CNRP candidates and members not to use "insulting and racially discriminating words" during the commune electoral campaign that will run from May 20 to June 2.

"There are some roads that others can walk, but we can't; and there are some activities that others can do but we can't; and there are some words that others can say, but we can't," he said.

Mr. Eysan said this was another piece of deception from Mr. Sokha.

"Ironically, KemSokha said he was unable to speak despite the fact that he was speaking" at the headquarters, he said. "Nobody bans him from speaking and there is no intimidation against him. He can speak freely."

Mr. Sokha "performs political activities freely, without fear, but says he's in fear," Mr. Eysan said. "So it's obviously a trick."

# បបរមាន់ស៊ុតខ្មៅ



គ្រប់ស្ត្រីមេផ្ទះ សុទ្ធតែធ្លាប់បានចម្អិនបបរ គ្រាន់តែថា បបរ ដែលគាត់បានចម្អិននោះ មានរសជាតិបែបណា និង ប្រភេទសាច់អ្វី។ ថ្ងៃនេះយើងខ្ញុំ សូមបង្ហាញនូវវិធីធ្វើម្ហូប មួយមុខដល់ស្ត្រីមេផ្ទះគ្រប់រូប ដែលមុខម្ហូបនេះមានឈ្មោះថា បបរមាន់ស៊ុតខ្មៅ។ បបរមួយនេះធ្វើចេញពីសាច់មាន់តែអ្វី ដែលប្លែកនោះគឺ វាមានបន្ថែមនូវស៊ុតខ្មៅពីលើៈ

**គ្រឿងផ្សំ**

▸ សាច់មាន់ ១ភ្លៅ ▸ ស៊ុតខ្មៅឆ្អិន ១គ្រាប់ ▸ ជីវ៉ាន់ស៊ុយហាន់រួច ១ស្លាបព្រាបាយ ▸ ជីរណា ១គល់ ▸ អង្ករ ១០០ក្រាម ▸ ស្ករស ១ស្លាបព្រាកាហ្វេកន្លះ ▸ អំបិល ១ស្លាបព្រាកាហ្វេ ▸ ម្រេចគ្រាប់ ៥ទៅ៦គ្រាប់ ▸ ម្រេចម៉ត់ស ១ ចុងស្លាបព្រា ▸ ខ្ទឹមស ៥កំពឹស ▸ ទឹកស៊ីអ៊ីវ ១ ស្លាបព្រា ▸ ខ្ទឹមបំពង ១ ស្លាបព្រា ▸ ស្លឹកខ្ទឹម ២ គល់។

**វិធីធ្វើ១**

ជាចំនុចចាប់ផ្តើមដែលអ្នកត្រូវធ្វើកាត់ហាន់ជីរណា ចិញ្ច្រាំខ្ទឹម ២កំពឹស និង ស្លឹកខ្ទឹមជាមុន។ យកសាច់ភ្លៅមាន់ពាក់កណ្តាលយកមកភ្លើយយកតែសាច់ រួចចិញ្ច្រាំ វាអោយម៉ត់ បន្ទាប់មករោយម្រេចស ជីវ៉ាន់ស៊ុយ ហើយដាក់ទឹកស៊ីអ៊ីវចូល ច្របល់ ចូលគ្នាឱ្យសព្វទុកអោយចូលជាតិធ្វើការមូលវាជាដុំតូចៗ។ **២.** ជាបន្តមកទៀត អ្នក ត្រូវដាក់ដាំទឹកអោយពុះ ក្រោយមកបង់ខ្ទឹមស (ដំឱ្យសំប៉ែត) ម្រេចគ្រាប់ ជីវ៉ាន់ស៊ុយ ភ្លៅមាន់ដែលនៅសល់ចូល បន្ថែមអំបិល រួចធ្វើការរំងាស់វា អោយចេញជាតិ និង ឆ្អិនសាច់។ ក្រោយពីសាច់ឆ្អិនហើយ អ្នកអាចស្រង់យកខ្ទឹម ជី និងសាច់ចេញ (ដើម្បី ធ្វើការបេះសាច់វាជាសរសៃ) ដាក់អង្ករដែលលាងរួចចូល ស្ងោរអង្ករឱ្យរីកក្លាយ ទៅ ជាបបរ និងដាក់ស្ករស សាច់ដែលមូលជាដុំៗចូល។ ពេលញ៉ាំអ្នកអាចពុះស៊ុតខ្មៅជា៤ ចម្រៀក បន្ទាប់មកយកមកដាក់ពីលើបបរ ហើយបន្ថែមសាច់ដែលហែករួច ស្លឹក ខ្ទឹម ជីវ៉ាន់ស៊ុយ ខ្ទឹមបំពង ម្រេចសពីលើ។

**គ្រឿងបន្ថែម** អ្នកអាចបន្ថែមខ្ញីហាន់ ឆាខ្វៃ ក៏ដូចជាស៊ុត១គ្រាប់ តាមចំណូលចិត្ត។




# តម្រឹមធ្មេញដោយមិនយកថ្លៃ

ប្រសិនបើលោកអ្នកឬគ្រួសារ មានអាយុ២១ឆ្នាំ ឬក្មេងជាង សូមទូរស័ព្ទមកយើងនៅថ្ងៃនេះ ដើម្បីរកមើលថាតើលោកអ្នកមានសិទ្ធនឹងទទួលបាននូវ "ប្រដាប់តម្រឹមធ្មេញ"ដោយ មិនចំណាយប្រាក់ ឬទេនៅពេលលោកអ្នកមាន "ម៉ាសហែល"? លោកអ្នកអាចនឹងទទួលសំណងរហូតដល់៤,៣០០ដុល្លា សម្រាប់ដាក់"ប្រដាប់តម្រឹមធ្មេញ"ទៅតាមសេចក្តីត្រូវការរបស់អ្នក។

The BRACES PLACE

វេជ្ជបណ្ឌិត មូហាប់ រីសកាឡា DDS MSD

## តើយើងធ្វើអ្វីខ្លះ?

ដាក់ធ្មេញដោយដែក * ដោយមាស * ដោយ"អិនវីសាឡាញ" * ដោយចាន

## អ្វីដែលធ្វើឱ្យយើងប្រសើរជាងនោះ?

- ឆ្លុះមើលបន្ថែម នឹង ជួបគ្រូពេទ្យ
- យើងទទួលយក"ម៉ាសហែល" នឹង "អិនស្វូរិន"ផ្សេងៗទៀត
- បង់ប្រាក់កក់មុនតិចបំផុត នឹងមានវិធីបង់ប្រាក់រំលោះប្រចាំខែសម្រាប់អ្នកដែលគ្មាន"អិនស្វូរិន" សូមទូរស័ព្ទ ឬក៏មកកន្លែងដែលស្រួលរករបស់យើង

710 Chelmsford St. Lowell, MA 01851

**(978)- 454 - 0774** (មានអ្នកនិយាយភាសាខ្មែរ)

ដើម្បីបានព័ត៌មានបន្ថែម, សូមចូលទៅ"វេបសាយ"យើង: www.bracesplaces.com

# ក្រុមហ៊ុនផលិតថង់យួរនៅឡូវែលត្រូវពិន័យសំណងចំនួន ១.២ លានដុល្លារ ចំពោះការបំពានច្បាប់ប្រាក់ឈ្នួល

## LOWELL REUSABLE BAG FACTORY TO PAY NEARLY $1.2 MILLION FOR NUMEROUS LABOR VIOLATIONS, RETALIATION AGAINST EMPLOYEES

**ឡូវែល**-រោងចក្រផលិតថង់យួរដែលមានទីតាំងនៅឡូវែលមួយមានឈ្មោះថា Un Wrapped, Inc. ដែលពលរដ្ឋខ្មែរស្គាល់ជាទូទៅថា ជាអាគារក្រហមបានយល់ព្រមបង់ប្រាក់ចំនួន $១.២ លានជាថ្នូលទៅនឹងការដោះស្រាយលើការរំលោបលើប្រាក់ឈ្នួលរបស់បុគ្គលិក, ច្បាប់បង់ប្រាក់ម៉ោង, ច្បាប់ធ្វើការលើសម៉ោង និងការបណ្តេញចេញបុគ្គលិកដែលបានចូលរួមក្នុងដំណើរការស៊ើបអង្កេតដែលកើតឡើងក្នុងកំឡុងខែមេសា ឆ្នាំ២០១៤ ដល់ខែមេសា ២០១៦។

ក្រុមហ៊ុន UnWrapped, ីនចដែលបានបង្កើតឡើងនៅឆ្នាំ ១៩៩៤ និងជាក្រុមហ៊ុនមានសកម្មភាពជាចំបងផលិតនិងលក់ថង់យួរដល់បណ្តាផ្សារទំនើប និងមានបុគ្គលិករៀបរយនាក់ដែលត្រូវបានជួលហើយបង់ប្រាក់តាមរយៈភ្នាក់ងារជ្រើសរើសបុគ្គលិកនោះ ត្រូវបានរកឃើញប្រព្រឹត្តល្មើសនឹងច្បាប់របស់រដ្ឋ។ ករណីនេះត្រូវបានធ្វើការស៊ើបអង្កេតដោយមានការសហការគ្នារវាងការិយាល័យអគ្គព្រះរាជអាជ្ញារដ្ឋម៉ាសាជូសេត និនាយកដ្ឋានប្រាក់ឈ្នួល និងប្រាក់ម៉ោងការងារ (United State Department of Labor’s Wage and Hour Division) ដែលបានចាប់ផ្តើមនៅខែមេសា ២០១៦ហើយជាលទ្ធផលបានរកឃើញថា កំឡុងខែ មេសា ឆ្នាំ២០១៤ដល់ ខែមេសា ឆ្នាំ ២០១៦អ្នកបម្រើការបណ្តោះអាសន្នក្នុងក្រុមហ៊ុន UnWrapped បានទទួលអាត្រាប្រាក់ម៉ោងទាបជាង ប្រាក់ឈ្នួលអប្បបរមាដែលកំណត់ដោយច្បាប់ ដោយក្រុមហ៊ុនបានប្រើប្រាស់ភ្នាក់ងារជ្រើសជើសបុគ្គលិកជាខែលក្នុងគោលបំណងគេចវេសពីបន្ទុករបស់ក្រុមហ៊ុន។

ការស៊ើបអង្កេតក៏បានរកឃើញដែរថា ក្រុមហ៊ុននេះ បានល្មើសនឹងច្បាប់ឈប់សម្រាក់ពេលមានជំងឺ ដោយមិនបានផ្តល់ទៅឱ្យបុគ្គលិករបស់ខ្លួននោះទេ និងបានបណ្តេញបុគ្គលិកដែលបានសហការ ក្នុងកំឡុងពេលការស៊ើបអង្កេតចេញពីការងារ។ ជាងនេះទៅទៀត ក្រុមហ៊ុនត្រូវគេរកឃើញថាបានប្រើប្រាស់កុមារអាយុ១១ឆ្នាំធ្វើការងារផងដែរ។

យោងតាមរបាយការណ៍របស់ការិយាល័យអគ្គព្រះរាជអាជ្ញារដ្ឋម៉ាសាជូសេតដែលចេញផ្សាយថ្ងៃទី ១០ ខែមិនា ឆ្នាំ ២០១៧លោក Steven Katz អគ្គនាយកក្រុមហ៊ុន UnWrapped, Inc បានយល់ព្រមបង់ប្រាក់ចំនួន $1.2 លាន ចំពោះការរំលោបច្បាប់ការងាររបស់រដ្ឋដែលក្នុងនោះ ក្រុមហ៊ុនតំរូវឱ្យបងប្រាក់ចំនួន $293,170 ចំពោះករណីការខកខានបង់ប្រាក់ឈ្នួលអប្បបរមា,មិនបានផ្តល់ការឈប់សម្រាក់ពេលមានជំងឺ និងការរើសអើមប្រឆាំងទៅនឹងបុគ្គលិក២រូប ដែលបានសហការក្នុងការសើបអង្កេត។ ប្រភពដដែរ ក៏បានឱ្យដឹងថា លោក Katz ក៏ត្រូវបង់ប្រាក់ចំនួន




$890,021 ចំពោះការបំពានច្បាប់ធ្វើការលើសម៉ោងរបស់សហព័ន្ធដោយបូកបន្ថែមនឹងការផាកពិន័យចំនួន $8,350 ចំពោះការរំលោបច្បាប់ពលកម្មកុមារផងដែរ។ លោក គាតឋ ក៏បានយល់ព្រមទទួលបុគ្គលិក២នាក់ដែលបានបណ្តេញចេញឱ្យចូលធ្វើការងារធម្មតាវិញ និងបងប្រាក់ម៉ោងការងារដែលខតខាងដល់អ្នកទាំង២ផងដែរ។

យោងតាមច្បាប់កាងារនៅម៉ាសាជូសេតប្រាក់ឈ្នួលអប្បបរមាដែលបានចូលជាធមានកាលពីខែ មករា ឆ្នាំ ២០១៧សម្រាប់អ្នកបំរើការងារភាគច្រើន បានកើនឡើងដល់១១ដុល្លារ ក្នុងមួយម៉ោង និង៨ដុល្លារ ក្នុងមួយម៉ោង សម្រាប់អ្នកបំរើការងារនៅក្នុងវិស័យកសិកម្ម។ សម្រាប់ការងារលើសម៉ោងអ្នកបំរើការងារភាគច្រើនដែលធ្វើការលើសពី៤០ម៉ោងក្នុងមួយសប្តាហ៍ត្រូវបង់ប្រាក់បន្ថែមសម្រាប់កិច្ចការលើសម៉ោងនោះដោយគិតអាត្រាយោងហោចណាស់១.៥គុណនឹងអាត្រាប្រាក់ម៉ោងធម្មតាសម្រាប់ម៉ោងនិមួយៗដែលលើស៤០ម៉ោងនោះ។

ច្បាប់ក៏បានអនុញ្ញាតឱ្យអ្នកបំរើការងារប្រើប្រាស់ការឈប់សម្រាក់ពេលមានជំងឺ(Earned sick time) ប្រសិនបើអ្នកបំរើការងារនោះ (រឺកូន, ប្តីរឺប្រពន្ធ, ឪពុកម្តាយ រឺឪពុកម្តាយរបស់ប្តីរឺប្រពន្ធ) មានជំងឺ, មានគគ្រោះថ្នាក់របួស រឺមានការណាត់ជួបជាមួយគ្រូពេទ្យជាទៀងទាត់ណាមួយនោះ។

ប្រសិនបើជឿជាក់ថាសិទ្ធរបស់លោកអ្នកត្រូវបានបំពាន់ក្នុងប្រការណាមួយនៅកន្លែងការងារ សូមទំនាក់ទំនងទៅកាន់ការិយាល័យតម្លាភាពការងារ (Fair Labor Division) តាមរយៈ Hotline (617) 727-3465។ លោកកអ្នកក៏អាចចូលទៅកាន់វ៉ិបសាយ www.mass.gov/ago/fairlabor សម្រាប់ព័តិមានទាក់ទងនឹងច្បាប់ប្រាក់ឈ្នួល និងប្រាក់ម៉ោងការងារសម្រាប់រដ្ឋម៉ាសាជូសេត៕









**តពីលេខមុន**

ខាងត្បូងកាត់វាលស្រែដែលមានកញ្ច្រាំងស្រូវទើបច្រូតកាត់រួចទំនងជាសំដៅទៅភ្នំស្រង់។ ចេញតែបន្តិចយប់ងងឹតក៏មកដល់ពុំមាននរណាមើលឃើញមនុស្សជាង៣០នាក់នោះ ដើរបន្តកន្ទុយគ្នាទៅដល់ណាហើយទេ ។ ថ្វីត្បិតតែលោកស្រីខ្វល់ជាខ្លាំងពីសុវត្ថិភាពរបស់ប្តីនៅក្នុងបេសកកម្មពេលយប់លោកស្រីនៅចាំដំណឹងពី "ប៉េសេ" ដែលមានវិទ្យុទាក់ទងគ្នាជានិច្ចដោយមិនសួរនាំលូកដៃក្នុងកិច្ចការរបស់ទាហ៊ានទេ។ រាត្រីដ៏សែនយូរមិនបាននាំដំណេកលោកស្រីឱ្យសម្រាន្តលក់លុងបានទេ ដោយសារតែកង្វល់នឹងព្រួយបារម្ភរហូតដល់ត្រជាក់បាតដៃបាតជើងតែបែកញើសមិនឈប់សោះ ។ ជិតភ្លឺកាន់ទេមកជិតគ្មានដំណឹងអ្វីសោះ ដូច្នេះក៏ជាដំណឹងល្អមួយដែរ... ស្រាប់តែម៉ោង៦ព្រឹក "កាប៉ុរ៉ាល់"ប្រចាំការម្នាក់រត់មកជម្រាបលោកស្រីថា លោកកុម៉ង់ដង់ត្រូវរបួសគេយកមកដល់ឥឡូវហើយ លោកស្រីស្ទើរផ្ទុះទ្រហោយំតែខំទប់តែនៅតែទប់ទឹកភ្នែកមិនបាន ក៏រត់ទៅចាំនៅ "បុស្តប៉េសេ" កូនទាំងអស់ដឹងរឿងក៏រត់ទៅទាំងអស់គ្នាប្រពន្ធទាហ៊ានឯទៀតក៏មកជួបជុំគ្នាយ៉ាងកកកុញដែរ... លោកកុម៉ងដង់មិនទាន់មកដល់គេនៅតែមិនដឹងជាទំហំរបួសនោះប៉ុណ្ណានោះទេ ។ លោកកុម៉ង់ដង់មកដល់បន្ទាយដោយអង្គុយលើកៅអីចងជាស្នែងលោកសណ្តូកជើងម្ខាងដែលប្រឡាក់សុទ្ធតែឈាមឱ្យទាហ៊ាន៤នាក់ជាអ្នកសែងលោកចេញមកពិខាងជើងរកាធំបន្តិចមកទៅវិញ, ដោយរវល់នឹងលោកកុម៉ង់ដង់ត្រូវរបួសគ្មាននរណាចាប់អារម្មណ៍ពីទាហ៊ាន "ប៉ាទ្រូយ" ចាប់បានឈ្លើយ២នាក់មកជាមួយនោះទេ...លោកកុម៉ង់ដង់បានត្រូវ គេហៅឡាន "អំប៊ុលឡង់" ទាហ៊ានមានសញ្ញាកាកបាតក្រហមធំៗជាឡាន "កាត់កាត់" យកលោកទៅមន្ទីរពេទ្យជាបន្ទាន់ដោយមិនបាននិយាយអ្វីជាមួយគ្រួសារលោកនៅឡើយផងទុកភារៈកិច្ចយោធាឱ្យបន្តរដោយ "ម៉ុង" ម្នាក់ធ្វើការជាអ្នកទទួលខុសត្រូវបន្ទាប់។ ពូសាយដែលនៅជាប់លោកកុម៉ង់ដង់ជារហូតមក ជា "អ័រដូណង់" គឺជាអ្នករាយការជូនលោកស្រីកុំឱ្យលោកស្រីមានការព្រួយបារម្ភខ្លាំងនឹងរបួសដែលលោកកុម៉ង់ដង់ ប្រាប់គេថា "ស្រាលទេកុំឱ្យគេភ័យ"។ ពូសាយជម្រាបលោកស្រីថា:

-លោកកុម៉ង់ដង់មានរបួសនៅជើង បន្ទាប់ពីបាញ់គ្នានៅ "ចំបក់" រួចមកមិនដឹងជាពីពេលណាមកទេ! ទាល់តែដើរចេញពី "ចំបក់" កន្លែងបាញ់គ្នាពេលនោះម៉ោងបួន-បួនកន្លះភ្លឺ រហូតមកដល់ជិតរកាធំ ទើបតេជគុណឱ្យសម្រាក



ហើយឱ្យរកកៅអីមកឱ្យលោកអង្គុយពេលនោះទើបខ្ញុំឃើញឈាមពេញស្បែកជើងទៅហើយ... តេជគុណឱ្យខ្ញុំដោះស្បែកជើងចេញកាត់ជើងខោម្ខាងនោះចោលជូតឈាមចេញឱ្យស្អាត ហើយរុំរបួសដោយត្រូវគ្រាប់នៅក្រោមជង្គង់ពេលនោះនៅមានឈាមនៅហូរតិចៗនៅឡើយ មិនទាន់ចប់ទេ... រុំរបួសឃាត់ឈាមរួចហើយ ទើបសែងតេជគុណ ចេញដំណើរបន្តពីចំបក់មក... តេជគុណមិនមានបាត់ស្មារតីទេ លោកមានទាំងទាកាហ្វេពិសារបានមួយកែវផង។

-ចុះហេតុអ្វីបានជាចេញទៅភ្នំស្រង់បែរជាទៅបាញ់គ្នានៅចំបក់ទៅវិញ? លោកស្រី ម៉ាំង សួរទៅពូសាយ

-បាទទាន ខ្ញុំមិនដឹងហេតុអ្វីទេទានដើរទាំងងងឹតឈឹងជាមួយអ្នកឯទៀត, តេជគុណមានសម្រាកពិសារកាហ្វេម្តងដែរទំនងជាម៉ោង៨យប់នៅ "ថ្នល់បំបែក" ស្រាប់តែម៉ោង២ភ្លឺទៅដល់ចំបកដែលនៅឯជើងទៅវិញ រង់ចាំឱកាស វាយឆ្មក់!...

-តើអាពីរនាក់ហ្នឹង ឬដែលបាញ់លោកកុម៉ង់ដង់នោះ? លោកស្រីកាត់,

-បាទមិនមែនទេ! ពេលវាយឆ្មក់នោះ គឺសំដៅចាប់ខ្លួនឱ្យបានគ្នាវាមាន៦-៧នាក់ ជាកូនចៅ "សក្តិ១ធិញ" ដែលកំពុងដេកក្នុងព្រៃនៅឡើយក្បែរដំបូកមួយ, ខាងគ្នាយើងមកជុំគ្នាមួយ "សិចស្យុង" (មានគ្នាជាង៣០នាក់បុងណោះ, ត្រៀមធ្វើការនៅទាបភ្លឺនឹងវាយលុកពញ្ញាក់កុំឱ្យតដៃ,...មេយផ្តើមភ្លឺស្រាងៗក៏ចាប់ប្តើមបាញ់... អាឯទៀតៗរត់អស់ នៅសល់អា២នាក់ហ្នឹងវាងើបមិនរួចដោយយើងបាញ់ចម្រុះគ្នា លើវាខ្លាំងពេក, ចំណែក "សក្តិ១ធិញ" ភ្ញាក់សើងមម៉ើង រត់យករួចខ្លួន ហើយបាញ់កាំភ្លើងខ្លីតបវិញ... ទំនងជាតេជគុណត្រូវគ្រាប់ពេលនោះ ទើបតេជគុណក្រោកឈរឡើងដេញបាញ់វា ហើយស្រែកថា "អាធិញហ្អែងបាញ់អញៗចាប់ហ្អែងឱ្យទាល់តែបាន!"... ដេញមិនទាន់អានោះរត់លឿនជាងក៏ទៅបាត់ ព្រោះវាខ្លាចដែរ មិនដឹងថា គ្នាយើងច្រើនប៉ុណ្ណាទេ? ...ស្ងប់ស្ងាត់ហើយ ទើបរៀបចំដើរត្រឡប់មកបន្ទាយវិញ...លោកកុម៉ងដង់នៅដើររធ្វើព្រងើយនៅឡើយ តែរាងខ្ញើចបន្តិចៗដែរ អ្នកឯទៀតមើលមិនដឹងទេ, ដើរបាន៣-៤គីឡូហើយមក ឮសូរសម្លេងទឹកក្នុងស្បែកជើង (មានឈាមច្រើន) ទើបដឹងថា តេជគុណត្រូវរបួស ហើយឱ្យគេសែងត្រឡប់មកបន្ទាយវិញ...

ឃើញប្តីមិនបាត់ស្មារតី ហើយដឹងថា ត្រូវរបួសរបៀបណាហើយ មានការកក់ក្តៅគ្រាន់បើបន្តិចឡើងវិញ ក៏នាំកូនៗត្រឡប់ទៅផ្ទះរៀបខ្លួនដើម្បីទៅមើលប្តីនៅឯមន្ទីរពេទ្យទាហ៊ាន ដែលនៅជាប់គ្នានឹងខាងត្បូងបន្ទាយទាហ៊ានជើងក្រហម ។ ថ្វីត្បិតតែលោកកុម៉ង់ដង់ត្រូវគ្រាប់ចៅពិនសង្កេតឃើញបរិយាកាសជ័យជំនះនាំទាហ៊ានមកបន្ទាយវិញបានទាំងអស់គ្នានៅមាននៅឡើយ, ប្រពន្ធទាហ៊ានញញឹមញញែមពេលបំបែកជួរបានជួបប្តីនាំប្តីមកផ្ទះវិញយ៉ាងអ៊ូអរលើកលែងតែលោកស្រីកុម៉ង់ដង់តែម្នាក់គត់នៅស្រងូតស្រង៉ាត់នៅឡើយ ធ្វើឱ្យទាហ៊ានមិនហ៊ានហោកញ្ច្រៀវខ្លាំងខ្លានៅពេលនោះទេ។

ម៉ោង១០ព្រឹក នៅមន្ទីរពេទ្យទាហ៊ានដែលស្អាតភ្លឹង តែធំក្លិនអល់កុល នឹងថ្នាំពេទ្យក្នុងពេទ្យដែលនៅជាប់នឹងបន្ទាយជើងក្រហមក្បែរ "វត្តម្រុំ" កុម៉ង់ដង់ ម៉ាំង ក្នុងសម្លៀកបំពាក់អ្នកជម្ងឺនៅពេទ្យកំពុងសម្រាកនៅឡើយ បន្ទាប់ពីការវះកាត់បន្ទាន់ នាមុខរបួសជើងខាងក្រោមក្បាលជង្គង់, លោកស្រីបានទៅដល់ជាមួយកូនប្រុស២នាក់, លោក កុម៉ង់ដង់ ទឹកមុខនៅស្លេកស្លាំងបន្តិចមែនតែនៅស្រស់បស់នៅឡើយ, លោកមិនបានភ្ញាក់ទទួលលោកស្រីនឹងកូនៗទេ, លោកស្រីអង្គុយបន្តិចលោកគ្រូពេទ្យបារាំងក្មេងម្នាក់ពាក់អាវបំពង់វែងសស្គុះមកដល់លោកបានមកគួរសមពន្យល់ភរិយាកុម៉ង់ដង់ដោយមានអ្នកបកប្រែម្នាក់មកជាមួយគ្រូពេទ្យនោះពន្យល់ថា

-ខ្ញុំគឺដុកទ័រ "ប៊្លួម"..."លោកកុម៉ង់ដង់" បានសុខសប្បាយហើយ យើងបានដេរមុខជិតហើយតែមានគ្រាប់កាំភ្លើងបាញ់ត្រូវជើងនោះនៅជាប់ក្នុងឆ្អឹងនៅឡើយ វានឹងមិនធ្វើឱ្យគ្រោះថ្នាក់ ឬក៏ដើរមិនបានអ្វីទៀតទេ...ថ្ងៃក្រោយពេលលោកកុម៉ង់ដង់មានកម្លាំងគ្រប់គ្រាន់យកគ្រាប់នោះចេញពេលណាក៏បាន...លោកស្រីសួរថា

-"តើនឹងយកគ្រាប់នោះចេញនៅឆាប់ៗខាងមុខ ឬក៏ទុកនៅយូរមិនរំខានអីទេ?

-នៅប៉ុន្មានអាទិត្យខាងមុខឆ្អឹងនឹងរឹងមាំនៅជុំវិញគ្រាប់នោះ ដូច្នេះត្រូវទុកឱ្យមុខរបួសជាឆ្អឹងត្រឡប់ទៅជារឹងមាំមកវិញ សឹមធ្វើការសម្រេចចិត្តថា ត្រូវយកគ្រាប់នោះចេញពីជើងនៅពេលណាវានឹងមិនរំខានលោកកុម៉ង់ដង់ទៀតទេ...ថ្ងៃនេះទុកឱ្យលោកកុម៉ង់ដង់សម្រាកឱ្យបានច្រើនបន្តិច...លោកស្រីក៏អរគុណលោកគ្រូពេទ្យ ហើយសន្យាថា ពេលល្ងាចនឹងត្រឡប់មកមើលប្តីម្តងទៀត...ស្របពេលហៀបនឹងចេញទៅកុម៉ង់ដង់បារាំងខាងជើងក្រហមលោកសក្តិ៤ "តូម៉ា" ពាក់ឯកសណ្ឋានកាគីសក្តិពេញស្មា ក៏មកដល់ល្មមបានរលាក់ដៃលោកស្រី ដោយធ្លាប់ស្គាល់គ្នាពីមុនមក ហើយនិយាយថា:

-ខ្ញុំមានសេចក្តីសោកស្តាយណាស់ ដែលលោកកុម៉ងដង់ ម៉ាំង ត្រូវរបួស តែលោកជាមនុស្សក្លាហានហើយឈ្លាសវៃណាស់! យើងនឹងតាមថែរក្សាគាត់ជាមួយលោកគ្រូពេទ្យ "ប៊្លួម" ឱ្យបានជាឡើងវិញ សូមលោកស្រីកុំបារម្ភ... លោកស្រី ម៉ាំង អរគុណលោក កុម៉ង់ដង់ "តូម៉ា" ហើយក៏លាចេញទៅបន្ទាយវិញទៅ...ចៅប៉ុននឹងចៅពិន ពីគ្រោះគ្នាតាមផ្លូវពេលជិះ "រ៉ឺម៉ក" ត្រឡប់មកបន្ទាយវិញ ចៅពិនសួរថា:

-តើគ្រាប់កាំភ្លើងអាច់នៅក្នុងសាច់បានដែរឬ? គាត់មិនឈឺទេឬអ្វី?

**តទៅលេខក្រោយ**

## តមកទំព័រទី ១៣ លោក កឹម សុខា ប្រាប់អ្នកគាំទ្រថា...

គណបក្សប្រឆាំងមួយនេះតែងតែទាក់ទាញចំណាប់អារម្មណ៍សាធារណជនម្តងហើយម្តងទៀតឱ្យផ្តោតលើការឈ្លានពានរបស់វៀតណាមមកលើព្រំដែនប្រទេសកម្ពុជា និងទំនាក់ទំនងនយោបាយរវាងរដ្ឋាភិបាលក្រុងហាណូយ និងគណបក្សប្រជាជនកម្ពុជា ហើយជួនកាលក៏មានការប្រើប្រាស់ពាក្យរើសអើងពូជសាសន៍ដែលជាយុទ្ធសាស្ត្រមួយក្នុងចំណោមយុទ្ធសាស្ត្រនយោបាយដ៏មានប្រសិទ្ធភាពរបស់ខ្លួនផងដែរ។

ប៉ុន្តែ លោក កឹម សុខា ទំនងជាមិនលើកទឹកចិត្តឱ្យសមាជិកគណបក្សរបស់លោកប្រើពាក្យបែបនេះនោះឡើងកាលពីម្សិលមិញ។

លោកបានមានប្រសាសន៍ថា "យើងមិនចាត់ទុកប្រទេសណាមួយជាសត្រូវរបស់យើងទេ ជាពិសេសប្រទេសជិតខាង ពីព្រោះយើងមានការគោរពគ្នាទៅវិញទៅមកដោយភាពថ្លៃថ្នូរ មានសុភាវធម៌គោរពអធិបតេយ្យភាព និងបូរណភាពទឹកដី"។

លោក កឹម សុខា ក៏បានណែនាំបេក្ខជន និងសមាជិកគណបក្សសង្គ្រោះជាតិកុំឱ្យប្រើប្រាស់ពាក្យ "អសុរោះជេរប្រមាថ និងពាក្យរើសអើងពូជសាសន៍"ផងដែរអំឡុងយុទ្ធនាការឃោសនាដែលនឹងចាប់ផ្តើមពីថ្ងៃទី២០ខែឧសភា រហូតដល់ថ្ងៃទី២ខែមិថុនា សម្រាប់ការបោះឆ្នោតឃុំសង្កាត់។

លោកបានមានប្រសាសន៍ថា "មានផ្លូវមួយចំនួនដែលអ្នកផ្សេងៗអាចដើរបាន ប៉ុន្តែយើងមិនអាចដើរបានទេ ហើយមានសកម្មភាពមួយចំនួនដែលអ្នកផ្សេងៗអាចធ្វើបាន ប៉ុន្តែយើងមិនអាចធ្វើបានទេ ហើយមានពាក្យខ្លះដែលអ្នកផ្សេងៗអាចនិយាយបាន ប៉ុន្តែយើងមិនអាចនិយាយបានទេ"។

លោក សុខ ឥសាន បានលើកឡើងទៀតថា នេះគឺជាឧបាយកលមួយទៀតរបស់លោក កឹម សុខា។

លោកបានមានប្រសាសន៍ថា "គួរឱ្យហួសចិត្ត កឹម សុខា និយាយថា គាត់មិនអាចនិយាយបានទេ ទោះបីជាការពិតលោកកំពុងនិយាយ" នៅទីស្នាក់ការកណ្តាលរបស់ខ្លួនក៏ដោយ។ លោកបានមានប្រសាសន៍បន្តថា "គ្មាននរណាម្នាក់ហាមឃាត់គាត់មិនឱ្យនិយាយនោះទេហើយគ្មានការបំផិតបំភ័យគាត់នោះឡើយ ។គាត់អាចនិយាយបានដោយសេរី"។

លោក សុខ ឥសាន បានសរសេរថា លោក កឹម សុខា "ធ្វើសកម្មភាពនយោបាយដោយសេរី ហើយគ្មានការភ័យខ្លាចនោះឡើយ ប៉ុន្តែគាត់និយាយថា គាត់ស្ថិតក្នុងភាពភ័យខ្លាច"។ លោកបានសរសេរបន្តថា "ហេតុដូច្នេះ វាពិតជាល្បិចកល"៕ **ស៊ុយឈាង**

## បើកទំព័រថ្មីសម្រាប់ទទួលយោបល់លោកអ្នកអាន

ដើម្បីចូលរួមស្វាគមន៍ឆ្នាំ២០១៧, យើងមានសេចក្តីរីករាយនឹងបើកទំព័រថ្មីម្រាប់ទទួលផ្សាយដោយសេរីនូវគំនិតយោបល់នឹងព័ត៌មានផ្សេងៗដែលលោកអ្នកអានមានបំណងធ្វើការផ្សព្វផ្សាយជាសាធារណៈនៅរៀងរាល់ពេលដែលយើងទទួលបាននូវអត្ថបទថ្មីពីលោកអ្នក។

សូមផ្ញើរអត្ថបទ រូបថត ឬ រូបគំនូរ មក info@khmerpost.us សម្រាប់អ្នកដែលចេះប្រើ "អាំងទែណេត" ឬក៏ផ្ញើរមកអស័យដ្ឋាន Khmerpost U.S.A. Editorial

45, Merrimack Street, #218A

Lowell, Lowell MA 01852_USA

សូមសរសេរដោយដៃក្នុងចន្លោះខាងក្រោមនេះរួចកាត់ផ្ញើរមកយើងខ្ញុំ

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

..................................................................................................

យើងជឿជាក់ថា គំនិត យោបល់ នឹងព័ត៌មានពីលោកអ្នកនឹងជួយជាប្រយោជន៍ដល់សហគមន៍ញាតិមិត្ត ក្រុមគ្រួសារជាមិនខាន។ សូមកុំភ្លេចដាក់ឈ្មោះ ឬដាក់រូបថត សម្រាប់សំគាល់ម្ចាស់អត្ថបទផង។ **-សូមអរគុណ-**

## តមកទំព័រទី ១១ រដ្ឋាភិបាលហាមន្ត្រីគណបក្សសង្គ្រោះជាតិ

ចោទថា ខ្ញុំធ្វើអ្វី ពីព្រោះខ្ញុំធ្វើការទៅតាមវិជ្ជាជីវៈសារព័ត៌មាន។ ខ្ញុំចង់ដឹងពីស្ថានភាពឱ្យខាងក្នុងពន្ធនាគារ។ អ្នកណាក៏ស្គាល់ខ្ញុំដែរ ធ្វើម៉េចខ្ញុំបន្លំខ្លួនទៅកើត"។

លោកស្រី មូរ សុខហួរ មានប្រសាសន៍ថា លោកស្រីគាំទ្រអ្វីដែលលោក ហួត វុទ្ធី បានរៀបរាប់ទាក់ទិនការចុះសួរសុខទុក្ខនេះ ប៉ុន្តែប្រាប់ថា គណបក្សសង្គ្រោះជាតិនឹងសហការជាមួយក្រសួងដើម្បីដោះស្រាយស្ថានភាពនេះ។

លោកស្រីលើកឡើងថា "យើងគ្មានចេតនាមិនគោរពបទបញ្ជាផ្ទៃក្នុងទេ។ យើងសង្ឃឹមថា ស្ថានភាពនេះនឹងត្រូវបានបញ្ជាក់...។ ហើយបន្ទាប់ពីមានការបញ្ជាក់នឹងមានដំណោះស្រាយ"។

សូមបញ្ជាក់ថា ក្នុងរយៈពេល១ឆ្នាំមកនេះ វិទ្យុអាស៊ីសេរី និងភ្ញៀវរបស់ខ្លួនបានជួបបញ្ហារហូត។ ជាក់ស្តែងលោក កែម ឡី ជាអ្នកវិទ្យាសាស្ត្រសង្គម និងជាភ្ញៀវប្រចាំក្នុងកម្មវិធីផ្សាយ "វេទិកាអ្នកស្តាប់" ដ៏មានប្រជាប្រិយភាពត្រូវបានខ្មាន់កាំភ្លើងបាញ់សម្លាប់កាលពីខែកក្កដា ពោលគឺតែប៉ុន្មានថ្ងៃប៉ុណ្ណោះក្រោយពីលោករិះគន់ថា រដ្ឋាភិបាលពុករលួយ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានព្រមានភ្ញៀវមួយរូបទៀតគឺលោក មាស នី កុំឱ្យ "ជ្រុលហួសហេតុពេក" ក្នុងសុន្ទរកថាមួយថ្លែងកាលពីខែវិច្ឆិកា ហើយបានប្តឹងលោក គឹម សុខ កាលពីខែកុម្ភៈ។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីបានអះអាងម្តងហើយម្តងទៀតថា វិទ្យុអាស៊ីសេរី និងវិទ្យុសំឡេងសហរដ្ឋអាមេរិក (VOA) កំពុងលួចធ្វើការជាសម្ងាត់ជាមួយរដ្ឋាភិបាលអាមេរិក និងគណបក្សប្រឆាំងដោយមានបំណងភាពបង្កចលាចល និងអស្ថិរភាពតាមរយៈការធ្វើសេចក្តីរាយការណ៍លម្អៀង។ រដ្ឋាភិបាលសហរដ្ឋអាមេរិកជាអ្នកផ្តល់មូលនិធិដល់ស្ថានីយវិទ្យុទាំងពីរ។

លោក ឡៅ ម៉ុងហៃ អ្នកវិភាគនយោបាយ និងជាភ្ញៀវប្រចាំក្នុងកម្មវិធីផ្សាយនានារបស់លោក ហួត វុទ្ធី មានប្រសាសន៍ថា និពន្ធនាយកកាន់តំណែងយូររូបនេះតែងតែរងការវាយប្រហារពីសំណាក់រដ្ឋាភិបាលដោយសារតែលោកមានភាពប៉ិនប្រសប់នៅក្នុងការរិះគន់មិនសំចៃមាត់គួរឱ្យទាក់ទាញ។

លោកលើកឡើងទៀតថា "ពិតណាស់ថា គាត់ជាមនុស្សម្នាក់ដែលរិះគន់រដ្ឋាភិបាលខ្លាំងៗ។ និយាយពីប្រជាប្រិយភាពខ្ញុំគិតថា គាត់បន្ទាប់ពីបណ្ឌិត កែម ឡី"៕ **សុខុម**

**កាសែតដែលបំរើសហគមន៍ខ្មែរមានអ្នកអានច្រើនជាងគេបង្អស់នៅឆ្នេរខាងកើតសហរដ្ឋអាមេរិកតាំង១០ឆ្នាំមកហើយ**

KhmerPost USA, LLC

សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

ផ្សាយពាណិជ្ជកម្ម Advertising

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

អ្នកនិពន្ធ Editorials

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

ការីនិពន្ធ Staff Writers:

អ្នកនិពន្ធកិត្តិយស **Contributing Writers:**

Richard Howe Jr,

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

**ជំនួយការរដ្ឋបាល** Office Coordnator

Sochet Chhen

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

Follow us: Facebook | Twitter @KhmerpostUSA

( អស័យដ្ឋានអ្នកផ្ញើរ )

បិតតែម

Khmerpost U.S.A., Editorial Dep.
45, Merrimack Street, #218A
Lowell, Lowell MA 01852_
USA

បត់ជា២..........................................................................

**អត្ថបទក្នុងសំបុត្រនេះ**
**១-** ជាអត្ថបទ ឬ ព័ត៌មាន សុំឱ្យចុះផ្សាយ
**២-** ជាសំនួរ សុំឱ្យឆ្លើយតាមទំព័រកាសែត
**៣-** ជាសំនួរ សុំឱ្យឆ្លើយតប មិនឱ្យផ្សាយទេ
សំបុត្រនេះអាចបត់ជាពីរ បិទការខាង២ បិតតែមមួយ រួចផ្ញើរមកយើងតាមប៉ុស្តិ៍
- សូមគូសនៅ ១-២ ឬ ៣ ដែលត្រូវនឹងសំបុត្រនេះ


# MARCOTTE LAW FIRM
## ក្រុមហ៊ុនមេធាវី Marcotte

45 MERRIMACK STREET
LOWELL, MASSACHUSETTS
(978) 458-1229

- សេចក្តីអន្តរាយដល់បុគ្គល
- សំណងបុគ្គល
- ពិការភាពដោយសន្តិសុខសង្គម
- បទព្រហ្មទណ្ឌផ្លូវភេទ និងថ្នាំញៀន
- ច្បាប់គ្រួសារ និងផែនការអចលនទ្រព្យ
- បណ្តឹងវិវាទទូទៅ
- ច្បាប់ធានារ៉ាប់រង
- ការរំលោភបទព្រហ្មទណ្ឌ
- គ្រោះថ្នាក់ចរាចរណ៍
- គ្រោះថ្នាក់នៅការដ្ឋាន
- បំណុលអចលទ្រព្យ
- បើកបរនៅពេលស្រវឹង និងប្រព្រឹត្តបទល្មើសពេលធ្វើចរាចរណ៍

**មានបុគ្គលិកនិយាយភាសាខ្មែរលោកអ្នកអាចហៅទូរស័ព្ទ មកក្រុមហ៊ុនយើងខ្ញុំដើម្បីពិគ្រោះ**

**(978) 458-1229**

**www.marcottelawfirm.com**

Element Care

# ខ្ញុំគ្មានការព្រួយបារម្ភទៀតទេ។



- ការផ្តល់សេវាធ្មេញដោយឥតគិតថ្លៃ
- ការផ្តល់ជូននូវយានជំនិះដោយឥតគិតថ្លៃ
- ផ្តល់ជូនវ៉ែនតានិងឧបករណ៍ជំនួយការស្តាប់ដោយឥតគិតថ្លៃ
- ការថែទាំតាមផ្ទះនិងផ្តល់ជូននូវអាហារដោយឥតគិតថ្លៃ
- ផ្តល់ជូននូវថ្នាំតាមវេជ្ជបញ្ជាដោយឥតគិតថ្លៃ

**នៅជាមួយនឹងកម្មវិធី PACE នៃអង្គការ Element Care, ការថែរក្សានឹងការចំណាយរបស់ខ្ញុំគឺត្រូវបានទទួលខុសត្រូវទាំងស្រុងជំនួសខ្ញុំ។**

អ្នកដែលមានសិទ្ធិមាន MassHealth នឹង Medicare គឺមិនត្រូវបង់ថ្លៃទេ។ សូមទាក់ទងមកយើងខ្ញុំបើអ្នកមានតែ Medicare ហើយនឹងការបង់ថ្លៃដោយឯកជន។ គ្រប់សមាជិកទទួលបាននូវការថែទាំសុខភាព, សេវាកម្មពេទ្យឯកទេស-លើកលែងតែសេវាកម្មសង្គ្រោះបន្ទាន់-ដូចជាបានអនុញ្ញាតពីកម្មវិធី PACE, ពុំនោះទេនឹងទទួលខុសត្រូវដោយខ្លួនឯងចំពោះថ្លៃសេវាកម្មមិនបានអនុញ្ញាតជាមុន។
H2222_2016_3K

សូមអញ្ជើញទាក់ទងមកកាន់ទូរសព្ទលេខខាងក្រោមនេះ:
1-877-803-5564
(TTY 711)
ឬក៏តាមរយៈ:
elementcare.org







## NOTICE OF PUBLIC REVIEW AND COMMENT PERIOD AND PUBLIC MEETING ANNOUNCEMENT

The Northern Middlesex Metropolitan Planning Organization (NMMPO) has released the Draft FFY 2018-2022 Transportation Improvement Program (TIP) for a 21-day public review and comment period. The TIP is a programming and management document containing all federally funded transportation projects planned over the next 5 years. Please note the TIP contains the program of projects for the Lowell Regional Transit Authority (LRTA).The NMMPO hasalso released the Draft FFY 2018 Unified Planning Work Program (UPWP) for a 21-day public review and comment period. The UPWP describes all transportation planning activities for the upcoming federal fiscal year. In addition, the NMMPO has released a draft listing of proposed Critical Urban and Rural Freight Corridors for public comment. This list defines roadway mileage to be designated as part of the National Highway Freight Network. This designation is necessary to be eligible for funding as provided in the Fixing America's Surface Transportation (FAST) Act.

Copies of the above draft documents are available online at www.nmcog.org. The public comment period runs through May 18, 2017. A public meeting on the draft documents will be held on

May 9, 2017, 5:30 PM, at the Northern Middlesex Council of Governments office, 40 Church St., Suite 200, Lowell, MA. You may also submit comments by phone at (978) 454-8021, ext 121, or by email: jhoward@nmcog.org. If preferred, comments may be mailed to the above address. The NMMPO's public participation process satisfies the LRTA's public participation requirements for the program of projects.

## សេចក្តីជូនដំណឹងស្តីពីកាលបរិច្ឆេទនៃការបញ្ចេញមតិ និងការពិនិត្យ និងការរៀបចំកិច្ចប្រជុំជាសាធារណៈ

អង្គភាពរៀបចំក្រុង ន័សធន មុីដូលសិច (Northern Middlesex Metropolitan Planning Organization) ហៅកាត់ NMMPO បានផ្សព្វផ្សាយពង្រៀងគម្រោងកម្មវិធីលើកកម្ពស់ការដឹកជញ្ជូន(ទីភ) FFY ឆ្នាំ២០១៨-២០២២ សម្រាប់ទទួលនូវមតិយោបល់ និងពិនិត្យជាសាធារណៈរយៈពេល២១ថ្ងៃ ។ កម្មវិធីលើកកម្ពស់ការដឹកជញ្ជូន (ទីភ) គឺជាឯកសារពីកម្មវិធី និងការគ្រប់គ្រង រួមមានគម្រោងដឹកជញ្ជូនដែលទទួលបានមូលនិធិពីសហព័ន្ធដែលគ្រោងសម្រាប់រយៈពេល៥ឆ្នាំក្រោយ ។ សូមបញ្ជាក់ថា ក្នុងគម្រោងទីភនេះ ក៏មានរួមបញ្ចូលទាំងកម្មវិធីនៃគម្រោងជាច្រើន សម្រាប់អាជ្ញាធរដឹកជញ្ជូនថ្នាក់តំបន់ឡូវែល (LRTA) ផងដែរ ។ អង្គភាព NMMPO ក៏បានផ្សព្វផ្សាយពង្រៀងកម្មវិធីផែនការសកម្មភាពនៃការបង្រួមបញ្ចូលគ្នាគម្រោង FFY ២០១៨ សម្រាប់សម្តែងមតិយោបល និងពិនិត្យជាសាធារណៈរយៈពេល២១ថ្ងៃ ។ កម្មវិធីផែនការសកម្មភាពនៃការបង្រួមបញ្ចូលគ្នា (UPWP) បង្ហាញរាល់សកម្មភាពផែនការដឹកជញ្ជូនទាំងអស់សម្រាប់ឆ្នាំសារពើពន្ធសហព័ន្ធនាពេលខាងមុខ ។ ជាងនេះទៅទៀត NMMPO បានប្រកាស់គម្រោងពង្រៀងដែលមានរាយបង្ហាញពីសំណើរគម្រោងការដឹកជញ្ជូនតាមជនបទ និងទីក្រុងសំខាន់ៗ (Critical Urban and Rural Freight Corridors) ដើម្បីទទួលបានយោបាលរពីសាធារណៈជន ។ ការរាយបង្ហាញនេះ កំណត់រយៈចម្ងាយផ្លូវដែលនឹងត្រូវរៀបចំជាប្លង់ដែលជាផ្នែកមួយនៃគម្រោងបណ្តាញដឹកជញ្ជូនតាមផ្លូវជាតិ (the National Highway Freight Network) ។ ការរៀចចំនេះ គឺវាសំខាន់ណាស់ដែលអាចឱ្យសមស្របទទួលបានមូលនិធិដូចដែលមានក្នុងច្បាប់ដឹកជញ្ជូនផ្លូវគោក (FAST) របស់ Fixing America ។

ច្បាប់ចម្លងនៃឯកសារពង្រៀងខាងលើមាននៅ online តាមរយៈវេបសាយ www.nmcog.org ។ រយៈពេលនៃការទទួលមតិយោបាលជាសាធារណៈនេះនឹងដំណើរការរហូតដល់ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៧ ។ កិច្ចប្រជុំជាសាធារណៈស្តីពីឯកសារពង្រៀងនេះ នឹងរៀបចំឡើងនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ ២០១៧ នៅការិយាល័យក្រុមប្រឹក្សាភិបាល ន័សធនមុីដូលសិច (Northern Middlesex Council of Governments) ដែលមានទីតាំងស្ថិតនៅផ្លូវ៤០ Church Street, Suite 200, Lowell, MA ។ លោកអ្នកក៏អាចផ្តល់ជាមតិយោបលតាមរយៈទូរស័ព្ទមកកាន់លេខ (978) 454-8021, ext 121 រឺអ៊ីម៉ែលមកអសយដ្ឋាន jhoward@nmcog.org ។ លោកអ្នកអាចផ្ញើសំបុត្រមកកាន់យើងខ្ញុំតាមរយៈអសយដ្ឋានខាងលើប្រសិនបើលោកអ្នកចងសរសរជាសំណូមពររឺមានយោបល់ ។ ដំណើរការចូលរួមជាសាធាណៈរបស់អង្គភាពរៀបចំក្រុងនេះ គឺវាស្របទៅនឹងតំរូវការឱ្យមានការចូលរួមជាសាធាណៈរបស់អាជ្ញាធរ LRTA សម្រាប់កម្មវិធីនៃគម្រោងជាច្រើនរបស់ខ្លួន ៕

## បានទទួលមួយ ឬទាំងពីរក្នុងចំណោមប័ណ្ណទាំងនេះ?

# ទទួលយកបន្ថែម។




ទទួលយកអត្ថប្រយោជន៍ច្រើនជាងអ្វីដែលអ្នកបច្ចុប្បន្នកំពុងទទួលបានពី Original Medicare និង MassHealth ជាមួយគម្រោង **UnitedHealthcare® Senior Care Options (HMO SNP)**។ វារួមបញ្ចូលគ្នានូវវេជ្ជបណ្ឌិតរបស់អ្នក មន្ទីរពេទ្យ និងការគ្របដណ្តប់ឱសថមានវេជ្ជបញ្ជាគ្រប់ទៅក្នុងគម្រោងមួយ គឺសម្រាប់ បុព្វលាភរ៉ាប់រងគម្រោង **$0**។**

### អត្ថប្រយោជន៍បន្ថែមអាចរួមមាន៖

**ឱសថមានវេជ្ជបញ្ជា**
រាប់ពាន់នៃឱសថអាចប្រើបាន។

**ការគ្របដណ្តប់លើទន្តសាស្ត្រ**
សហចំណាយ **$0** សម្រាប់ការដាក់ធ្មេញ និងក្រាសធ្មេញពាក់។

**ជំនួយលើមធ្យោបាយធ្វើដំណើរ**
សហចំណាយ **$0**សម្រាប់ការជិះទៅជួបវេជ្ជបណ្ឌិតតាមការណាត់។

**កាតាឡុកផលិតផលសុខភាព**
រហូតដល់ទៅ **$160** ក្នុងឥណទានប្រចាំឆ្នាំដើម្បីទិញ ផលិតផលសុខភាពពីកាតាឡុករបស់យើង។

**ទូរស័ព្ទមកថ្ងៃនេះដើម្បីចុះឈ្មោះ ឬទទួលបានចម្លើយទៅនឹងសំណួររបស់អ្នក។**



BOPHA PEOU
Licensed Sales Agent # 2016784

**Contact # (978) 221-9970, TTY 711**
[8 a.m. – 8 p.m. local time, 7 days a week]

**UHCCommunityPlan.com/MA**

UnitedHealthcare
Community Plan

UnitedHealthcare SCO គឺជាគម្រោងថែទាំសុខភាពដែលមានការសម្របសម្រួលមួយ ដែលមានកិច្ចសន្យាជាមួយ Medicare និងជាប់កិច្ចសន្យាជាមួយកម្មវិធី Commonwealth of Massachusetts Medicaid ។ ការចុះឈ្មោះនៅក្នុងគម្រោងគឺផ្អែកទៅលើការបន្តកិច្ចសន្យាជាថ្មីរបស់គម្រោងជាមួយ Medicare ។ គម្រោងនេះគឺជាកម្មវិធីស្ម័គ្រចិត្ត ដែលអាចរកបានសម្រាប់អ្នកដែលមានវ័យចាប់ពី 65 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ MassHealth Standard និង Original Medicare ។ ប្រសិនបើលោកអ្នកមាន MassHealth Standard ប៉ុន្តែលោកអ្នកមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបាន Original Medicare លោកអ្នកនៅតែមានសិទ្ធិចុះឈ្មោះក្នុងគម្រោង MassHealth Senior Care Option និងទទួលបានអត្ថប្រយោជន៍ MassHealth ទាំងអស់របស់លោកអ្នកតាមរយៈកម្មវិធី SCO របស់យើង។ ព័ត៌មាននេះគឺមិនមែនជាការពិពណ៌នាពេញលេញអំពីអត្ថប្រយោជន៍នោះទេ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកគម្រោង។ ការកំណត់សហចំណាយ និងការដាក់កំហិតនានាអាចត្រូវអនុវត្ត។ អត្ថប្រយោជន៍ បុព្វលាភរ៉ាប់រង និង/ឬសហចំណាយ/សហធានារ៉ាប់រងអាចផ្លាស់ប្តូរនៅថ្ងៃទី 1 ខែមករានៃឆ្នាំនីមួយៗ។ បុព្វលាភរ៉ាប់រង សហចំណាយ សហធានារ៉ាប់រង និង ថ្លៃបង់ប្រចាំឆ្នាំមុនពេលធានារ៉ាប់រងបង់ឲ្យ អាចប្រែប្រួលតាមកម្រិតនៃជំនួយបន្ថែមដែលលោកអ្នកទទួលបាន។ សូមទាក់ទងមកគម្រោងសម្រាប់ព័ត៌មានលំអិតបន្ថែមទៀត។ អ្នកចុះឈ្មោះមិនតម្រូវឲ្យបង់ប្រាក់ពីហោប៉ៅឡើយ។

H2226_150915_093829 Accepted
UHCSCO_150915_093829

CST10056_ H2226-001

សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA

Cambodian American Biweekly Newspaper

## ផ្សព្វផ្សាយទៅដល់អ្នកអានក្នុងសហគមន៍ខ្មែរច្រើនជាងគេបង្អស់នៅសហរដ្ឋអាមេរិក

កាសែតខ្មែរផុស ស.រ.អា គឺជាកាសែតភាសារខ្មែរ- អង់គ្លេសពណ៌ធម្មជាតិ មានចំនួន៣២ទំព័រដែលបោះពុម្ពផ្សាយជារៀងរាល់ពីរសប្តាហ៍ម្តងចំនួន៥,០០០ច្បាប់ និងធ្វើការបែងចែកដោយមិនគិតថ្លៃទៅកាន់៦០កន្លែងក្នុងតំបន់ឡូវែល។ រៀបចំពេលវេលាផ្សព្វផ្សាយពាណិជ្ជកម្មសម្រាប់ឆ្នាំ២០១៧ របស់លោកអ្នកជាមួយយើងខ្ញុំថ្ងៃនេះ!

Connecting 10,000 Khmer-speaking households per Month with an average of 5 members per household. Free Newspaper copies are available in these cities:

Massachusetts:

- Lowell
- Lynn/Revere

Rhode Island:

- Providence
- Cranston



<u>កាលបរិច្ឆេទនៃការបោះពុម្ពផ្សាយ :</u>

- ថ្ងៃទី ៧ និង ២១ ខែមេសា
- ថ្ងៃទី ៥ និង ១៩ ខែឧសភា
- ថ្ងៃទី ៩ និង ២៣ ខែមិថុនា
- ថ្ងៃទី ៧ និង ២១ ខែកក្កដា
- ថ្ងៃទី ៤ និង ១៨ ខែសីហា
- ថ្ងៃទី ៨ និង ២២ ខែតុលា
- ថ្ងៃទី ៦ និង ២០ ខែកញ្ញា
- ថ្ងៃទី ៣ និង ១៧ ខែវិច្ឆិការ
- ថ្ងៃទី ៨ និង ២២ ខែធ្នូ

**<u>2017 Print Dates</u>**

- April 7, 21
- May 5, 19
- June 9, 23
- July 7, 21
- August 4, 18
- September 8, 22
- October 6, 20
- November 3, 17
- December 8, 22

* រាល់ព័ត៌មាននៃការផ្សព្វផ្សាយទាំងអស់ ត្រូវផ្ញើមកកាន់យើងខ្ញុំឲ្យបាន ៣ ថ្ងៃមុនការបោះផ្សាយ។

**ទំនាក់ទំនងមក ពិន សុបិន សម្រាប់ឱកាសនៃការផ្សព្វផ្សាយពាណិជ្ជកម្មរបស់លោកអ្នក**

**Contact Soben Pin For Advertising Opportunities**
**Email:** sobenpin@khmerpost.us
**978-677-7163**

ម៉ោងបំរើការងារ: ថ្ងៃច័ន្ទ - សុក្រ ចាប់ពី 9:00 ព្រឹក ដល់ម៉ោង ៤:០០ ល្ងាច
អសយដ្ឋានការិយាល័យ**កាសែតខ្មែរផុសស.រ.អា**

Office: KhmerPost USA, LLC. 45 Merrimack St. Suite 218A. Lowell, MA 01852
Hours: Monday – Friday. 9AM – 4PM

**VISIT KHMERPOST.US**

KhmerPost USA

សូមគោរពអញ្ជើញ លោក លោកស្រី ចូលរួមរាត្រីស្រមោលស

## ខួបទី១០ឆ្នាំ នៃការបង្កើត សារព័ត៌មានខ្មែរផុស ស.រ.អា

ថ្ងៃសុក្រ ទី19 ខែឧសភា ឆ្នាំ 2017
**6:00 -12:00 ល្ងាច**

**នៅសណ្ឋាគារ យូម៉ាស ឡូវែល**
50 Warren Street Lowell, Massachusetts


**ពិនសុបិន**
សហស្ថាបនិក/នាយកគ្រប់គ្រង


**ពិន សំខុន**
សហស្ថាបនិក/និពន្ធនាយក

**5:30** ពិសារ ( ខុកថែល ) - ជាមួយអាហារសំរន់
**6:30** ការសម្តែងរបាំប្រពៃណី
អាហារពេលល្ងាច
ការរាំកំសាន្តជាមួយក្រុមភ្លេងតន្ត្រីខ្មែរ
អាចទិញភេសជ្ជៈជូនពិសារបាន

ស្លៀកពាក់ របៀបប្រពៃណីខ្មែរ ឬរបៀប ( បូលរោម )
តម្លៃសំបុត្រ $75 ក្នុងមួយនាក់ $700 សម្រាប់ 10 នាក់
មិនមានការលក់សំបុត្រនៅថ្ងៃកម្មវិធីនោះទេ

សូមទាក់ទងដើម្បីជាវសំបុត្រឲ្យបានមុនថ្ងៃពុធ ទី10 ខែឧសភា
សំខុន ពិន: **978-942-1641** | សូបិន ពិន: **978-677-7163**
សម្រាប់ព័ត៌មានបន្ថែមសូមចូលទៅគេហទំព័រ khmerpost.us




### FEATURED SPEAKERS


**Andy Pendelton**
*Former United Nations Field Coordinator Thai Refugee Camps (1980-1990s)*


**Hong Net**
*City of Lynn Councilor-at-Large*


**Cheryl A. Burrell**
*Associate Director Rhode Island Dept. of Administration Office of Diversity, Equity and Opportunity (ODEO)*

## សូមថ្លែងអំណរគុណដល់ម្ចាស់ឧបត្ថម្ភ

***ម្ចាស់ឧបត្ថម្ភ Silver Sponsor***
**Senior Whole Health**

***ម្ចាស់ឧបត្ថម្ភ Bronze Sponsors***
**Dolan Funeral Home • Fallon Health • Lowell Spinners**
**Lynn Primary Care Center**